Reçu le 17-1-52.

INDOCHINE FRANÇAISE
DÉPÔT LÉGAL

# ព្រះរាជាណាចក្រ កម្ពុជា

មន្ទីរស្ដីការក្រសួងសិក្សាធិការ

"Tossanéavedday"

# ទស្សនាវដ្ដី

សម្រាប់

គ្រូបង្រៀន

ឆ្នាំទី ៣ លេខ ៣

ខែវិច្ឆិកា ព.ស. ២៤៩៥

ឆ្នាំសិក្សា ១៩៥១ - ១៩៥២.

# ព្រះរាជអាណាចក្រកម្ពុជា

មន្ទីរស្ដីការ ក្រសួងសិក្សាធិការ

## ទស្សនាវដ្ដី សម្រាប់ គ្រូបង្រៀន

## បញ្ជីរឿង


| | ទំព័រ |
|---|---|
| វិធីបង្រៀនអក្សរថែបថ្មីនៅកុមារដ្ឋាន (សេចក្ដីណែនាំ) | ៣ |
| ឧត្តមដ្ឋាន - មជ្ឈិមដ្ឋានទី ២ ភាសា | ១១ |
| មជ្ឈិមដ្ឋានទី ១ អាទិកដ្ឋាន ភាសា | ១៩ |
| កុមារដ្ឋាន - បរិបូណ្ណដ្ឋាន ភាសា | ៣០ |
| អាទិកដ្ឋាន - មជ្ឈិមដ្ឋានទី ១ នព្វន្តវង្វាស់វង្វាល់-ធរណីមាណសាស្ត្រ | ៤១ |
| កុមារដ្ឋាន បរិបូណ្ណដ្ឋាន - នព្វន្ត - វង្វាស់វង្វាល់ | ៥០ |
| មជ្ឈិមដ្ឋានទី ២ - ឧត្តមដ្ឋាន - វិទ្យាសាស្ត្រ - វិធីបង្ការរោគ | ៦៧ |
| អាទិកដ្ឋាន - មជ្ឈិមដ្ឋានទី ១ - វត្ថុស្វាធ្យាយន៍ - វិធីបង្ការរោគ. | ៧១ |
| បរិបុណ្ណដ្ឋាន - កុមារដ្ឋាន - វត្ថុស្វាធ្យាយន៍ វិធីបង្ការរោគ | ៨៤ |
| លោកនីតិ សំរាប់គ្រប់ថ្នាក់ | ៩០ |
| មេសូត្រត់មាត់ | ៩៣ |

# វិធីបង្រៀនអក្សរបែបថ្មីនៅកុមារដ្ឋាន

## មេរៀន ទី ៤៥

### អង អង់ អាង អាំង

ក្ទង ក្មេង ខ្នង ខ្លាំង គ្រឿង ឃ្នាង ឃ្លង ច្បាំង ឆ្នាំង ជ្រុង ឈ្នាង ត្បូង ត្រែង ថ្នង ថ្លាង ទ្រូង ធ្យូង ប្ដឹង ប្រេង ផ្អៀង ផ្សែង ក្ងើង ម្ដង ល្បែង ល្ងង់ ស្នែង ស្អាង ៗ ចង្កង់ ចង្អង់ ចង្កៀង ៗ

ចីគង់ជិះកង់ទៅលេងកំពង់ឃ្លាំង ៗ គេលីថ្នង់ទៅដងត្រីក្ទង់បឹង ៗ នាងគេងផ្អៀងផ្អងនៅខាងត្បូងចង្កៀង ៗ មីងថោងខឹងនឹងបង ៗ ពូបេងប្រឡូងធ្វើបង់តុង ៗ ពៅក្រែងក្ងើងផ្សែង ៗ បងខ្ញុំចង់ពិសានំបាំង ៗ

---

## មេរៀន ទី ៤៦

### អញ អញ់ អាញ អាញ់

ក្រាញ ក្រាញ់ ខ្មាញ់ ខ្លាញ់ ប្រាញ ឆ្ងាញ់ ជ្រួញ ឈ្មួញ ត្បាញ ត្អូញ ធ្មេញ ចញ ផ្លាញ់ ព្រួញ ភ្លើញ ម្រេញ ម្យាញ់

ស្មោញ ក្រញ៉ាញ់ ប្រមូញ ប្រដេញ សំណាញ់ ស្រឡាញ់ អង្គុញ អង្កាញ់ អញ្ចាញ ។

គេទិញខ្លាញ់ត្រីពីក្រុងភ្នំពេញៗ សំឡាញ់ចីថនអ្នូញថាឈើស្មោញ ។ សំពៅនេះចេញទៅព្រៃនគរវិញៗ ខ្ញុំឃើញត្រីឆ្ញូញប្រដេញគ្នា ។ ពួក្រាញ់ទៅបង់សំណាញ់ ។ឈ្មួញនេះដួញចំណេញកន្ទុំផ្តាំម្យាញ់ ។ចីម៉ាញបញ្ចេញខោឡាញ់ថ្មី ។

---

## មេរៀន ទី ៤៧

# អន អន់ អណ អាន អាន់

ក្បាន ក្ដាន់ ខ្ទួន ខ្ទិន គ្មាន គ្រុន ប្រើន ប្រាន ផ្អិន ឈ្មាន់ ថ្វាន់ ថ្ងៃន ទ្រាន់ ប្រាណ ប៉ុន ផ្ទួន ព្រួន ក្ងន កើន លឿន ល្អន់ ស្គន់ស្ពាន ស្ពាន់ ស្មៀន ស្ទូន់ ស្ទាន ត្រីកោណ បង្ហាន់ សណ្ដាន់ ។

បង់ទៅកែសានទៅបាញ់ក្ដាន់បានបួន ។ ទាហានសនត្រុនបាញ់ពេះប៉ៃលិន ។ ទោ(រ)ប៉ុន់តាមាន់នៅស្គន់ ។ យើងលាងខ្លួនប្រាណងឹងសាប៊ូ ។ ថៃយ៉ាន់បានសែនព្រេនពីខែមុន ។ ដង្កៀវពិនបង់ក្បួននៅខាងលើស្ពានថ្មូ ។ គេស្មានថាបង្ហាន់មិនទាន់ផ្អិន ។

មេរៀនទី ៤៨

## អម អិម អាម អាិម

ក្ដាម ក្រៀម ក្រោម ក្អម ខ្ទម ខ្ទឹម ខ្ពើម ខ្លម ច្បាម ប្រម ផ្អើម ត្រឹម ថ្គាម ថ្លើម ទ្រោម ធ្នឹម ប្លម ផ្ដើម ផ្អូម ផ្អែម ព្រម ភ្លាម ព្រាម ម្អម ល្មម ស្គម ស្នាម ស្រោម ចម្លង បង្អែម ។

តាសោមសង់ខ្ទមនៅក្រោមដើមអង្កាញ់ ។ បង្អែមបែតមផ្អូម ។ អាកេមចម្លងមេរៀនភ្លាម ។ ស្មៀនសែមមិនចេះនៅស្ងៀម ។ នាងពេនថ្នមប្អូនពៅ ។ ជើងពានស្ពាន់នេះដុះស្និម ។ ស្រោមនេះល្មមនឹងជើងអាឡម ។

---

មេរៀនទី ៤៩

## អក អក់ អខ អឃ អគ

អ្នក ក្ងោក ក្ងៀក ក្អែក ខ្យាក់ ខ្លែក ប្យូក ឆ្នុក ជ្រូក ឈ្លក់ ត្យក ថ្លុក ធ្លាក់ ប្រាក់ ប្លោក ផ្គាក់ ផ្អក ព្រែក ក្នែក ម្នាក់ លើក ល្អក់ ស្កក ស្នូក ស្បែក ស្លៀក មុខ មេឃ រោគ បង្កក់ អន្ទក់ ។

តាម៉ុកយកបង្កួកទៅចាក់ត្រីឆ្តោ ។ ស្អែកចីចុកក្រោកពីព្រឹកទៅព្រៃកក់ ។ ក្មេងណាស្មោកគ្រោកច្រើនមានរោគ ។ បែស្មុកក្ដុកនំគ្រក់ ។ ក្អកចុះទៅផឹកទឹកថ្នុក ។ អ្នកនេះស្មៀកពាក់ប៉ូកពីគេ ។ អ្នកស្រុកលង្អែកវែកឃ្លោកទៅលក់ ។ ខ្ញុំស្រក់ទឹកភ្នែកស្រោក ។

មេរៀនទី ៥០

## អត អត់ អជ អថ អទ អឌ

ក្ដាត ក្អាត់ ខ្ចាត់ ខ្ចិត ឃ្មាត ប្រត់ ប្រូត ឆ្នោត ឆ្អែត ឃ្មេត ត្នោត ត្នាត ទ្រុត ប្រិត ប្តាត ផ្ចិត ផ្សិត ព្រោត ភ្ជាត់ ល្បាត លុត ស្ងួត ស្មៀត ស្អាត ជីគិជ្ជ ស្បថ សមុទ្រ គ្រុឌ អណ្ដាត បង្កាត់ ។

ត្នោតនេះស៊ីមិនទាន់ឆ្អែត ។ គេដាំដើមត្នោតជិតមាត់សមុទ្រ ។ ត្រីស្លាតមានជាតិជាងត្រីឈ្លាត ។ ចីម៉ែតឆ្មៀតបង្រៀនកូនធ្វើបំណាច់ ។ តូចឈ្មុំស្បថលែងទិញត្នោតទៀត ។ នាងគាតហែកសំពត់បីហត្ថខ្នាត ។ គេដើ (រ) កាត់ព្រៃស្ងាត់ ។

### មេរៀនទី ៥១

## អច អច់ អាច អាច់ អជ អាជ

កួច ក្បាច់ ក្រួច ខ្ទួច ខ្មោច ខ្លោច គ្រោច ឃ្លៀច ឃ្លិច ច្រាច់ ឈ្លោច ត្រាច ថ្ពេច ធ្មោច ប្រាជ្ញ ព្រួច ភ្លោច ម្ដេច ម្រេច ល្ងាច លួច ស្ដេច ស្នាច ស្រួច ស្អួច ពូជ សង្កើច សន្ទូច បង្អួច ។

គេបាចទឹកបញ្ចេញពីស្រែដោយស្នាច ។ ចៃទូចក្លេចស្រោចស្ទឹក-ស្រែ ។ ល្ងាចនេះបងខ្ញុំទៅបេះក្រូចឃ្លិច ។ ដីឡាចឈ្លេចសង្កើច ។ កា-ម៉ាចមិនអាចនៅទីនេះព្រោះវាខ្លាចឃ្មុំទិច ។ ចូ(រ)អ្នកកុំលួចសន្ទូចគេ ។ — ហេតុម្ដេចបានជានាងក្ដិចប្អូន? ។

---

### មេរៀនទី ៥២

## អប អប់ អិប អិប់ អព អភ

ក្ដិប ក្អែប ខ្ចប់ ខ្សឹប គ្រប់ ឃ្លុប ឃ្នាប ច្បាប់ ច្រឹប ឆ្អាប ជ្រាប ឈ្លុប់ គ្រប់ ថ្កៀប ទ្រាប ធ្នាប់ ភ្ជាប់ ទ្រាប់

ផ្គាប់ ផ្អាប់ ព្រាប ម្ហូប ល្បប ស្វាប ស្នប់ ស្រោប ស្ទាប សន្ដាប់ បង្កាប់ បញ្ចប់

ប្រអប់ស៊ីវិឡាតនេះគ្មានគ្រប ។ អ្នកធ្មបចាប់យកអង្ក(រ)បីក្ដាប់ ។ ទាហានឈ(រ)ត្រៀបត្រាក្នុងម្លប់ ។ ពូព្រាបលេបថ្នាំគ្រុនពីគ្រាប់ ។ គេរៀបប្រាប់ខ្ញុំថាតាក្លែបស្លាប់ ។ អ្នកចំកា(រ)ខ្ចប់ម្ហូបទៅបរិភោគ ។ យើងធ្លាប់ខ្លាចច្បាប់ទំលាប់ ។

---

មេរៀនទី ៤៣

## អយ អាយ អិយ អ៊ាយ

ក្លាយ ខ្ចាយ ខ្ឈាយ ខ្នាយ ខ្សោយ ធ្លាយ ធ្លើយ ធ្វាយ ជ្រាយ ជ្រោយ ឈ្លើយ ណ្ហើយ គ្រួយ ថ្វាយ ទ្រាយ ធ្លាយ ប្រាយ ផ្កាយ ផ្សាយ ព្រួយ ក្នាយ ល្បោយ ល្វើយ ស្កួយ ស្នាយ ស្ពាយ ស្រួយ ស្អុយ បន្ទួយ សម្ពាយ ។

យាយប្រក់ស្រោយសំពាយ ។ ផ្ទះមេគយនៅក្រោយបន្ទាយ ។ ខ្មួយវាពួនទៅក្រោមខ្នើយ ។ ចិត្តយព្រួយព្រោះកូយឈើ ។ ខ្ញុំស្ដាយដោយពុំបានទៅស្ពាយរៀនជាមួយនឹងម្ដាយខ្ញុំ ។ យើងមានឃើញផ្កាយដុះកន្ទុយជាយូ(រ)ហើយ ។

## មេរៀនទី ៤៨

# អវ អាវ អិវ អឹវ

កែវ ខៀវ ខ្វាវ ខ្វែវ ខ្យែវ ចែវ ច្រាវ ជ្រាវ ដាវ ត្រាវ ត្រូវ ថ្កូវ ធាវ ប្រាវ ផាវ ផ្ទូវ ផ្អាវ ព្រាវ ភ្ញៀវ ភ្លាវ លាវ ស្កូវ ស្លូវ ស្រៀវ ប្រដៀវ សាវ ក្តាង សាវម៉ាវ ខ្យែវគាវ ដំឡាវ រង៉ាវ ។

តាព្រាបដកដាវសផ្កាវ ។ នៅស្រុកលាវគេដាំដើមសាវម៉ាវជា-ច្រើន ។ យាយកែវពាក់កាវតាំងពីក្មេង ។ គេផ្ទុកបាវស្រូវក្នុងទូកថ្វៃ ។ ពូខៀវដើ(រ)តាមផ្លូវរទេះទៅភូមិស្រយូវ ។ ចីពាវពាក់អាវមិនដាក់ខ្សែវ ។ ផ្ទាវក្តុំភ្នាក់មុនមានរង៉ាវ ។

---

## មេរៀនទី ៤៩

# អល អល់ អាល អាល់

ក្បិល ក្រាល ខែល ខ្ចិល ខ្វាល់ ខ្ញល ខ្យល ឃ្វាល ច្រាល ឆ្កៀល ឆ្នាល់ ឆ្ទល ឆ្វែល ជ្រុល ឈ្នាល ត្បាល់ ត្រៀល ថ្ពាល ទ្រាល ផ្ទុល ផ្អើល ព្រាល ភ្ចល់ ភ្ញល់ ម្ចុល ស្គាល់ ស្ទួល ស្រាល កន្ទុល សម្រួល ។

យើងត្រូវផុសក្អែលពាល់ថ្ងៃពីក្បាលរហូតដល់ចុងជើង ។ លោកគ្រូខ្ញាល់ព្រោះអាប៉ុលពខ្ញិល ។ យាយកែវស៊ីត្រាវទាល់តែស្កល់ ។ អ្នកស្រែមិនដែលស្គាល់ត្រីព្រួល ។ តាគ្រៀលស៊ីឈ្លួលឃ្លាលពពែ ។ ពូព្រិលបញ្ចូលគោឈ្នាលក្នុងក្រោល ។ ផ្តិលនេះស្រាលស្កើក ។

មេរៀនទី ៥៦

## អស អស់ អិស អិស់

គ្រាស កូស់ ខូស់ ឆ្កូស់ ខ្មោស ខ្មូស គ្រៀស ច្បាស់ ប្រាស ឆ្នាស ឆ្ងាស់ ជ្រើស ឈ្មោស ឈ្ងូស ត្រួស ថ្នាស ថ្ងស់ ទ្រើស ធ្នួស ប្រាស ផ្តាស់ ព្រួស ភ្លាស់ មួស ល្បាស ល្មើស ស្រាស់ ក្រដាស អំបោស ទោស ។

សិស្សនេះសសេរលើក្រដាសក្រាស់ ។ យាយឡាចកោសដូងដោយខ្មោស ។ មនុស្សចាស់មិននិយាយផ្តេសផ្តាសទេ ។ នាងសយ-ម្ហើយច្បាស់ណាស់ ។ គេប្រស់ត្រីស៉ៃនៅក្នុងស្រះ ។ ម្តាយខ្ញុំជ្រើស-រើសយកតែម្ទេសស្រស់ ។ ឈ្លូសស៊ីល្ហាស់ឈើក្បែរព្រៃធំ ។

## មេរៀនទី ៥៧

ឌឺដង ឌិន ឥត ឥណ្ឌូចិន ឥន្ទធនូ ឥសី ឥឡូវ ឦសាន ឧប ឧន ឧយ ឧកញ៉ា ឧដុង្គ ឧត្ដរ ឧបមា ឧបាសក ឧបាយ ឧស្សាហ៍ ឪ ឪទឹន ឪពុក ឪម៉ាល់ ឪឡ ឪឡឹក ឫកពា ឫស្សី ឬទេ ឭ រឭក រំឭក ឮ ឯ ឯក ឯង ឯកឧត្ដម តាំងឱ ឱកាស ។

ពូឌិននិយាយឌឺដងឲ្យយប់ឌិម ។ លោកតាឧនឥតមានឱកាសទៅឧដុង្គ-សោះ ។ ឧកញ៉ាឌីឧយទៅទិញថ្នាំឥសីផ្សំស្រេច ។ ឪម៉ាល់ទិចក្បាលដីឯក ។ នៅប្រទេសឥណ្ឌូចិនគេដាំឪឡឹកគ្រប់ដម្បន់ ។ ឧបាសកសែមទៅជីកទំពាំងឫស្សី ។ ឯងរំឭកឪពុកឬទេ ។

---

# ឧត្ដមញ្ញាន

## សតិសម្បជញ្ញៈ

កាលណោះ ពានរមួយ ហៅមហាកបិន្ទ កបដោយកម្លាំងក្លាហាន អាស្រ័យនៅព្រៃត្រើយស្ទឹងធំមួយ ។ ស្ទឹងនោះមានកោះកបដោយផ្លែ

ឈើបរិបូណ៌ ពានរតែងផ្លោះអំពីត្រើយទៅកោះតាមថ្មមួយនៅជាប់នោះ ត្រើយនឹងកោះ ដើម្បីនឹងស្វែងផលាផលរាល់ៗថ្ងៃ ។

ថ្ងៃ១ក្រពើមានបំណងនឹងចាប់ស្វាស៊ី ។ កុម្ភាក៏ហែលលីលាត្រង់ទៅទីដុំថ្មដែលពានរតែងលោតផ្លោះតាមថ្មនោះ ដល់ហើយក្រពើឡើងក្រាបលើថ្ម ដើម្បីឲ្យពានរលោតទៅលើខ្លួននឹងចាប់ស៊ី ។ ឯមហាកបិន្ទលុះបរិភោគផលាផលស្កប់ស្កល់ហើយក៏វិលទៅត្រើយនាយវិញ ។ មកដល់ច្នេរស្ទឹងនឹងលោតទៅជាន់ដុំថ្មដូចសព្វដង ពានរបែរទៅឃើញថ្មនោះខ្ពស់ ក៏កើតក្តីសង្ស័យគិតថា ថ្មនេះហេតុអ្វីក៏ខ្ពស់ដូច្នេះ ទំនងជាមានសត្វកំណាចក្រាបលើថ្មនេះ ដើម្បីនឹងយាយីជីវិតអាត្មាអញជាប្រាកដ ។ ពានរក៏ពោលពាក្យហៅទៅថា ហៃដុំថ្មដ៏ប្រសើរអើយ ខ្លួនចៅឯងនេះសព្វកាលរៀងមកពុំដែលខ្ពស់ទេ ក៏ថ្ងៃនេះហេតុអ្វីថ្មឯងលូតខ្ពស់លើសកាលមុនៗហ: ។ ពានរពោលមិនតែម្តង ពោលហៅដល់បីដង ។ កុម្ភាគិតថាប្រហែលជាថ្មធ្លាប់និយាយប៉ុន្តែឯងក្រាបលើវា ៗ និយាយពុំបាន ដូច្នេះអញនឹងនិយាយជួសវា គិតហើយឆ្លើយតបថា: "ហៃមហាកបិន្ទអញ្ជើញលោតជាន់លើយើងដូចកាលមុនៗនោះចុះ" មហាពានរឮក៏ថា

“ភោ ! នរណាពោលពាក្យតនឹងយើងនេះ ថ្មៈយើងមិនចេះនិយាយទេ នេះគឺរូបនរណា ពោលប្រាប់មកយើងនេះ” ក្រពើទាល់បញ្ញានឹងគេចខ្លួនមិនរួច ទើបឆ្លើយប្រាប់តាមក្ដីពិតថា: យើងនេះជាតួមហាកុម្ភា នៅនាទីស៊ឹងនេះ ៗ មហាកបិន្ទក៏ថា: “ឱលោកកុម្ភាទេវៈ ! អើក៏ហេតុអ្វីលោកមកដេកក្រាបលើថ្មនេះ ៗ នែលោកពានរ យើងនេះមានសេចក្ដីប្រាថ្នាចង់បានសាច់ថ្លើមបេះដូងនៃរបស់លោកឯងនឹងនាំទៅឲ្យភរិយាយើងបរិភោគ ៗ ឱបើលោកប្រាថ្នាជីវិតយើងដូច្នោះ ចូរលោកហាមាត់ធ្មេចភ្នែកឡើង យើងនឹងលោតទៅត្រង់ឥឡូវនេះ ៗ ក្រពើក៏តាំងហាមាត់ឡើងចង្ក្រានធំ ធ្មេចភ្នែកចាំងពីរប្រុងចាំត្របាក់ពានរ ៗ ឯមហាពានរបានឱកាសហើយក៏លោតផ្លោះស្ទុះទៅលើទីពាបត្រង់ទៅជាន់លើក្បាលកុម្ភា ហើយផ្លោះទៅដល់ត្រើយនាយ ដោយកម្លាំងខ្លាំងលឿនដូចខ្យល់មួយរំពេច ក៏ទៅដល់ទីលំនៅនៃអាត្មា ៗ

ឯមហាកុម្ភាដឹងជាមហាកបិន្ទលោតផុតខ្លួនហើយ ខ្លួនចាប់ពុំបានដូច្នោះ ក៏កើតក្ដីទោមនស្សត្រូវចិត្ត ដោយចាញ់កលមហាកបិន្ទ ក៏ចុះពីខ្នងសិលាម្នីម្នាហែលទៅកាន់ទីរូងក្បាលកោះ ជាទីលំនៅនៃអាត្មាវិញហោង ៗ

## ពាក្យពន្យល់ .–

សតិសម្បជញ្ញៈ .– សេចក្ដីដឹងមិនភ្លេចខ្លួន

ពានរ = ស្វា ។ ពានរា = ស្វាឈ្មោល , ពានរី = ស្វាញី ។ កបិ ស្វា ( កបិ + ឥន្ទ = កបិន្ទ ប្រែថា ស្វាដ៏ជាធំ )។ កុម្ភា = ក្រពើឈ្មោល កុម្ភី = ក្រពើញី ។ ផលាផល = ផ្លែឈើទាំងឡាយ ។ យាយី = បៀតបៀន ។ អាត្មា អត្ត តនុ = ខ្លួន ។ ទោមនស្ស = តូចចិត្តចាញ់កល ចាញ់ប្រាជ្ញា ចាញ់បោក ។ សិលា = ថ្ម ។

## ការបង្កើតឡើងដ៏ជាទំហំ

បណ្ដាការបង្កើតឡើងជាទំហំ គេរៀបជាលំដាប់ គឺត្រីវិសៃ រំសេវឬមេ្យរសម្រាប់បាញ់កាំភ្លើង ក្រដាសធ្វើដោយកំណាត់សម្ពត់ ពុម្ពអក្សរ ។ តាមពិត ពុម្ពបោះអក្សរតែម្យ៉ាងនេះឯង ជាការបង្កើតឡើងអំពីជាតិអ្នកអឺរ៉ុបក្នុងរវាងសតវត្សរ៍ ១៥ ។ ការបង្កើតឡើងឯទៀតទាំងបីនោះ សឹងមកពីបូព៌ាប្រទេស ហើយសឹងជាការមានមកពីមុនយូរហើយ ។ ប៉ុន្តែក្នុងសតវត្សរ៍ ១៥ ដែលការបង្កើតឡើងជាទំហំទាំងឡាយនោះ ប្រើពាសពេញទាំងសកលអឺរ៉ុប ។

ចិនបានដឹង បានចេះរួចហើយ ថាទ្រនិចមេដែក កាលណាទៅឯកឯងគំរើកតាមចិត្តបាន មានគុណសម្បត្តិតែងតម្រង់ចុងទៅទិសឧត្តរជាកប ។ ជាតិអារ៉ាប់បានយកការនោះគឺត្រីវិស័យមកអំពីចិនហើយបានវិចិត្រសម្រួលឲ្យស្រួលទៀតនៅសកពជ ១៣០០ ដោយជាតិអីតាលីយ៉ាង ដែលធ្វើត្រីវិស័យជាដម្បូងឡើងគឺទេរទ្រនិចថ្លឹងស្មើលើ - បង្គោលដាំជាប់ហើយគ្របដោយកញ្ចក់ ។ ត្រីវិស័យអាចឲ្យអ្នកសមុទ្របរដឹងទិសបានពល់វេលាហើយអាចឲ្យធ្វើបានដំណើរឆ្ងាយយូរលង់ ទឹងរកឃើញការកំបាំងនៃមហាសាគរ ។

រំសេវឬម្សៅ វត្ថុផ្ទុះ កើតពីក្រាមពីស្ពាន់ធ័រនឹងធ្យូងលាយគ្នាជាការកើតឡើងអំពីចិនដែរ ។ វត្ថុនេះចូលទៅដល់អឺរ៉ុបដោយជាតិអារ៉ាប់ ។ តាំងពីសតវត្សរ៍ ១៤ មកជាតិអីតាលីយ៉ាង, បារាំងសែស' អង់គ្លេសតាំងចាប់ប្រើកាំភ្លើងធំដែលមានសូរស័ព្ទខ្លាំងអាក្រក់ ក្នុងពជ្យស្តេចហាលទី ៧ ពួកសមណៈប៉ុយរ៉ូ បានដាក់កាំភ្លើងលើជើងគុលវិលបាន ដែលធ្វើយ៉ាងនេះសម្រាប់ជាគ្រឿងប្រើទៅគ្រប់ជម្បន់ ។ គេបានធ្វើកាំភ្លើងដៃកាំភ្លើងវែងជាដើមអាទ៍នៃកាំភ្លើងអុជឈ្មួន ។ អាវុធភ្លើងក៏ផ្លាស់ប្តូរលក្ខណៈតាមការបម្រាំង ប៉ុន្តែបែបទ្រង់ទ្រាយតែបន្តិចៗមកតាំងពីសតវត្សរ៍ ១៤ ដល់មកសតវត្សរ៍ ៧ ។

នៅមជ្ឈិមសម័យ គឺសម័យក្នុងចន្លោះ សម័យបូរាណនិងសម័យស៊ីវិល្យ.បច្ចុប្បន្ន គេប្រើតែសៀវភៅសរសេរដៃ គេចម្លង សរសេរលើផ្ទាំងស្តើងអំពីស្បែក ដោយហេតុនោះផ្ទាំងសំរាប់សរសេរនោះថ្លៃណាស់ ហើយរកបានដោយកម្រ ៗ ប៉ុន្តែយូរណាស់មកហើយ ចិនចេះធ្វើក្រដាសដោយចំរៀកព្រៃឬសំពត់កប្បាស ជាតិអារ៉ាប់ប្រើក្រដាសធ្វើដោយកប្បាស ។

ពាក្យពន្យល់.-

ការបង្កើតត្រីវិសៃ = គ្រឿងប្រដាប់សំរាប់ប្រាប់ទិស គុណសម្បត្តិ ចំណេះវិជ្ជា, ទ្រព្យ អានុភាព ការកំបាំង= របស់លាក់បិទបាំង សមណ:= អ្នកបួស ។

ពាក្យចោទសួរ.-

ជាតិណាដែលបានរកឃើញការបង្កើតឡើងជាដម្បូង = ត្រីវិសៃ? រំសេវ? ក្រដាស? ពុម្ពអក្សរ?- កាលមុនបង្កើតត្រីវិសៃ អ្នកសមុទ្រ បរដឹងទិសដោយអ្វី? ការប្រើផ្កាយប្រចាំទិសឬផ្កាយមេរុ ជាប្រដាប់ប្រាប់ទិស មានទាស់ការអ្វីដែរ ឬដូចម្ដេច ?

# មជ្ឈិមដ្ឋានទី ២

## ត្រិះរិះសិនមុនសម្តែងគំនិត

បណ្ឌិតសភាវិទ្យាសាស្ត្រ បានដាក់ចំណោទប្រឡងមួយឲ្យគេដូចមានតទៅ ៗ ចំណោទថា ផើងមួយទឹកពេញ ហើយបើអ្នកបង់អ្វីមួយ ឬថ្មមួយដុំទៅក្នុងផើងទឹកនោះ ទឹកក្នុងផើងពោរហៀរចេញពីផើង ប៉ុន្តែបើអ្នកយកត្រីមួយទំហំប៉ុនថ្មបង់ទៅក្នុងផើងដដែល ទឹកក្នុងផើងមិនពោរហៀរចេញឡើយ ចូរអ្នកអធិប្បាយហេតុនោះ ៗ សេចក្តីអធិប្បាយឆ្លើយមកមានបរិបូរ ៗ អ្នកប្រាជ្ញទាំងឡាយបញ្ជូនមកសេចក្តីអធិប្បាយហេតុទាំងផលបរិបូរណ៍ណាស់ដើម្បីស្រាយចំណោទប្លែកនោះ ខ្លះថាត្រីស្រូបទឹក ទើបទឹកមិនពោរហៀរចេញ ខ្លះថាត្រីជក់ទឹកមកខ្លួនរាប់ដូចមេដែកដែលជក់ទាញយកកំទេចដែក ៗ ការរកចំណោទនេះអស់ឆ្នាំប្រាំតៗមក បណ្តាអ្នកប្រាជ្ញទាំងនោះ គ្មានអ្នកណាមួយឆ្លើយត្រូវឡើយ រង្វាន់ក៏នៅខានពុំបានទៅនរណា ៗ នៅក្នុងកម្លុងពេលនោះ ព្រឹទ្ធាចារ្យម្នាក់ដែលតែងតែផ្ញើរមកពលឆ្នាំ ការណ៍កើតថ្មីៗ មានចិត្តគិតស្របចំណោទ ដោយសុកទិច្ច័យការណ៍ដែលត្រូវធ្វើដូចសព្វដង ៗ ព្រឹទ្ធាចារ្យ

យកកែវពីរប៉ុនគ្នាមកដាក់ទឹកពេញ ហើយយកថ្មមួយដុំទំងន់ត្រឹមមួយទំហំ ស្មើមកបង់ក្នុងកែវទឹក ។ លុះបង់ថ្មក្នុងកែវមួយទៅ ទឹកពោរហៀរពីកែវ រួចបង់ត្រីទៅក្នុងកែវមួយទៀត ទឹកក៏ហៀរពីមាត់កែវដូចគ្នាដែរ ។

បណ្ឌិតសភាបង់បង្ហាញឲ្យឃើញថា ទឹងរកឃើញការពិត មានតែត្រិះរិះមុនឬសម្តែងគំនិត ។

ពាក្យពន្យល់ ៖—

សភា = សាលា (សភាវិទ្យាសាស្ត្រ, រដ្ឋសភា, ធម្មសភា)

បរិបូរ = កិរិយាសព្ទ ឬ គុណនាម បរិបូរណ៍ = គ្រប់គ្រាន់ ។

សុភនិច្ឆ័យ = លំអានចិត្ត (bon sens) ។ ព្រឹទ្ធាចារ្យ = មនុស្សដែលគេរាប់អានដោយមានជរាវិជ្ជា ។ ការណ៍ = ហេតុ ។

ពាក្យចោទសួរ ៖— ក្នុងរឿងនេះអ្នកយល់ឃើញនូវអ្នកប្រាជ្ញទាំងនោះដូចម្តេច ?

ចុះព្រឹទ្ធាចារ្យម្នាក់នោះធ្វើការដោយចិត្តដូចម្តេច ក៏បានរកចំណោទឃើញ សុភនិច្ឆ័យ គឺធ្វើដោយពុំមានអំនួត ដោយលំអានចិត្ត) ។ ក្នុងរឿងនេះ គេទូន្មានយើងដូចម្តេច ?

# មជ្ឈិមដ្ឋានទី ១

## រៀនមើល – ពាក្យភាសា

### ពាក្យទំនៀមហៅ

### ត្រីរស់ក៏រួប ទន្សាយក៏រួប

មានរឿងមួយនិទានថា: កាលណោះមានបុរសម្នាក់ដាក់អន្ទាក់ជាប់បានទន្សាយមួយ ទន្សាយនោះពុតធ្វើជាស្លាប់ ។ បុរសដឹងពុតទន្សាយក៏យកវាទៅក្រុងក្នុងអង្រុតជាប់ ។ គាប់ជួនថ្ងៃនោះបុរសនោះបានត្រីរស់យកមកប្រោះទុកក្នុងថ្នង ដាក់ប្របនឹងអង្រុតដែលក្រុងទន្សាយនុះផង ។ បុរសចង់ល្បងយាមលោកគ្រូមើលក៏ទៅរកលោកគ្រូចាប់យាមដល់ហើយក្រាបថ្វាយបង្គំលោកគ្រូបទូលថា៖ ព្រះតេជព្រះគុណ ក្នុងវេលាព្រឹកនេះខ្ញុំព្រះករុណា នឹងមានលាភបានអ្វីទទួលទានឬទេ? –

លោកគ្រូចាប់យាមហើយឆ្លើយប្រាប់ថា "ថ្ងៃនេះបាសកឯងគ្មានលាភបានវត្ថុអ្វីផ្អកស៊ីទេ, ស៊ីតែបាយនឹងអំបិល" ។

បុរសនោះញញឹមគិតថាយាយលោកគ្រូមិនធុតទេ អញមិនប្រគេនសម្លសាច់ទន្សាយ នឹងត្រីស្ងោរត្រីរស់ឆាន់ទេ, ហើយក៏ថ្វាយបង្គំលាលោកគ្រូត្រឡប់មកផ្ទះវិញ ។

បុរសប្រើប្រពន្ធឲ្យដណ្តាំបាយ ហើយឯខ្លួនឯងយកត្រីរស់ទៅស្រ-កានៅប្របមាត់ត្រពាំងនាមុខផ្ទះ ត្រីលោតផ្លាតរបូតចុះទៅក្នុងទឹក ។ បុរសនោះស្រែកហៅប្រពន្ធឲ្យយកអង្រុតមកឲ្យជាប្រញាប់ ប្រពន្ធភ្លេចគិតដល់ទន្សាយ ក៏ស្ទុះទៅយកអង្រុតទៅឲ្យប្តី នោះទន្សាយក៏បោលរបូតទៅ ។ ប្តីនឹងប្រពន្ធឃើញទន្សាយបោលរបូតដូច្នោះ ក៏រត់ដេញតាមទន្សាយ ៗ រត់បាត់ទៅ ត្រឡប់មកវិញត្រី ៗ ក៏បាត់ទៅដែរ ។ បុរសប្តីនឹងប្រពន្ធមានក្តីទោមនស្សដោយខាតចាកលាភដូច្នេះ ក៏ពោលពាក្យថា "យើ យាយលោកគ្រូអញធុតណាស់តើ" ។

## ពន្យល់ពាក្យ

ទំនៀម = បវេណី, សណ្តាប់, សណ្តាប់ធ្នាប់ ។

អន្ទាក់ = ប្រដាប់ធ្វើដោយខ្សែ ឬដោយចម្រៀកផ្តៅវាដើមមានក្រវិលរូតបាន សម្រាប់ទាក់, សម្រាប់ដាក់ ឲ្យជាប់សត្វទ្វិបាទ ចតុប្បាទជាដើម ។

ទន្សាយ = (ម. ថ. ទន់សាយ) ឈ្មោះសត្វតូចជើង ៤ មិនផឹកទឹក ផឹកតែសន្សើម ។

ពុត = កិច្ចកលមាយាទ ។

អង្រុត = (ម. ថ. អង់រុត) ទេសាឧបករណ៍មួយបែប ធ្វើដោយ បន្ទោះឫស្សីមូលៗ មានពងក្រឡូម តូចខាងមាត់លើ ធំគាយខាងក្រោម សម្រាប់រុតឬក្រុងមច្ឆជាតិ ។

ចាប់យាម = សង្កេតពេលយាមតាមក្បួនតម្រាហើយទាយ ។

ព្រះតេជព្រះគុណ = (ម ថ. ព្រះដែចព្រះគុណ) គុណនៃ អំណាចដ៏ប្រសើរលើសលន់ ឬ អំណាចនឹងគុណដ៏ប្រសើរខ្ពង់ខ្ពស់ ។

បាសក = (ម. ថ. បាសក់) គ្រហស្ថ: ពាក្យដើមជាឧបាសក គេកាត់តួ “ឧ” ចេញ: ពួកបាសកដើរវត្ត ។

## ហាត់ភាសា.-

រឿងនេះគេនិយាយអំពីអ្វី ? — បុរសម្នាក់ដាក់កន្ទាក់ជាប់បានអ្វី? ទន្សាយនោះយ៉ាងដូចម្តេច ?- ហេតុម្តេចបានជាបុរសនោះយកទន្សាយនោះ ទៅក្រុងនឹងអង្រុត?- បុរសនោះមិនបានអ្វីដែរក្នុងថ្ងៃនោះ?- យកត្រីរស់ នោះទៅទុកក្នុងទីណា ? ព្រោះអ្វីបានជាបុរសនោះទៅរកលោកគ្រូចាប់

យាម ?– លោកគ្រូទាយដូចម្ដេច ?– បុរសនោះគិតថាដូចម្ដេច ?– បុរសនោះត្រឡប់មកផ្ទះវិញរួចធ្វើដូចម្ដេច ?– បុរសនោះបានសំរេចប្រយោជន៍ដូចបំណងឬទេ ? ព្រោះហេតុអ្វី ?– ។ល។

---

# ភាគិកដ្ឋាន

## បង្រៀនពាក្យ – ហាត់ភាសា

### អាទិត្យទី ១ .– អំពីភូមិ

នាម .– ភូមិ, ឃុំ, ស្រុក, ខេត្ត, សាលាឃុំ, មេឃុំ, ផ្លូវ, ផ្លូវថ្នល់, ផ្លូវដើរ, របង, ទ្រុង, ក្រោលគោ ក្របី, រដូវវស្សា, រដូវប្រាំង, រដូវរំហើយ ។

គុណនាម .– ទូលាយ, ចង្អៀត, ពិបាក, ងាយ, ស្រួល, ខ្ពស់, ទាប, ។

កិរិយាសព្ទ .– កភូមិ, សង់ផ្ទះ, ដើរកាត់ភូមិ, ចុះពីផ្លូវធំ, ឡើងមកផ្លូវធំ, ធ្វើរបង ។

ហាត់និយាយ .– អ្នកនៅភូមិណា? ភូមិនោះធំឬតូច? មានផ្ទះប្រហែលប៉ុន្មាន? អ្នកស្រឡាញ់ភូមិអ្នកឬទេ? សាលាឃុំនៅត្រង់ណា? អ្នកដែលទៅសាលាឃុំឬទេ? គេទៅសាលាឃុំដើម្បីអ្វី? នៅភូមិអ្នកមានផ្លូវថ្នល់ឬទេ? មានផ្លូវដើរប៉ុន្មាន? មកសាលារៀនអ្នកដើរតាមផ្លូវណា? នៅជុំវិញភូមិអ្នកមានរបងឬទេ? ព្រោះហេតុអ្វី? ក្នុងរដូវវស្សាទឹកលិចភូមិអ្នកឬទេ? ព្រោះហេតុអ្វីបានជាទឹកមិនលិច? ហេតុអ្វីបានជាមានភូមិខ្លះទឹកលិច? អ្នកស្រឡាញ់ភូមិអ្នកឬទេ? ព្រោះអ្វី? ។

## បង្រៀនៈមើល

សៀវភៅវិជ្ជាខេមរភាសាបរិច្ឆណ្ឌានទំព័រ ១២

កែដម្រូវ = កុំពង់កំពុង ៗ = ថ្នរ = ថ្ន ៗ ផុក = ភក់ ។

ពន្យល់ពាក្យ= ភូមិ = ទីដែលមានប្រជុំផ្ទះលំនៅក្នុងតំបន់និមួយ ៗ

ក្រុង = កិ. គ្របះដោយប្រដាប់មាខអង្រ្រិត់ជាដើម ហើយសង្កត់ទប់ទុក "ក្រុងមាន់ឬក្រុងត្រី" ក្រុង = (ច្រើនអានថាគ្រុង) ន. នគរ រាជធានី បុរី "ក្រុងប៉ារីស ក្រុងព្រៃនគរ ក្រុងភ្នំពេញ" ។

ថ្លុក = ទីដ៏ក្រហូងដែលដក់ទឹកក្នុងរដូវវស្សា ប៉ុន្តែតូចជាងត្រពាំង ។

ត្លុក = អ្នកក្រមាច់, អ្នកកំប្លែងក្នុងល្បែងរបាំដើម្បីឲ្យគេសើច ។

## សរសេរតាមសូត្រ

អំពីភូមិខ្ញុំ (សៀវភៅដែលទំព័រ១២) តាំងពី ភូមិខ្ញុំនៅជិតក្រុង .... រហូតដល់ ពិបាកដើរទៅភូមិឬឡើងមកផ្លូវធំ ។

សរសេរពាក្យពិបាក .— ផ្លូវកាត់ភូមិ, ក្រាលថ្ម, ដើរ, រដូវវស្សា, ដក់ទឹក, ភក់ ។

## តែងសេចក្ដី

ចូរបំពេញឃ្លានៅក្នុងចន្លោះខាងក្រោមនេះ៖ ភូមិខ្ញុំនៅជិត .. ...-ដែលមកពីភ្នំពេញទៅឯ .... ។ នៅក្នុង . . . មានផ្ទះ . . . ផ្ទះទាំងនោះ . : . . . ខ្ពស់ពីដីហើយមាន . . . . ព័ទ្ធជុំវិញ ។កាល-ណាភ្លៀងផ្លូវទាំងប៉ុន្មានក្នុងភូមិ . . . . . ដើរណាស់ព្រោះផ្លូវទាំងនោះមាន . . .ច្រើន

## អក្សរផ្សំ

ប ប ម ឋ បិ

ប បា បី បុ បូ បើ បែ បៃ បោ បៅ បំ

ភូមិបោមបៅ មឹងមៅបំបៅកូន កុំបេស បបើងបង់លាភ

### អាទិត្យទី ២.— អំពីផ្សារ

នាម .— ផ្សារ, ផ្លូវទេះឡាន, សសរ, តង្គ, បាយអ, ដំបូល, គ្រឿង ជញ្ជាំង, ល្វែង, អ្នកលក់, អ្នកទិញ, ត្រី, សាច់, បន្លែ, ផ្លែឈើ ៗ

គុណនាម .- ធំ, ទូលាយ, ចំហ, បិទជិត, ស្រស់, ក្រៀម, ឆាប់, រស់ៗ

កិរិយាសព្ទ .— ទៅផ្សារ, មកពីផ្សារ, លក់ទំនិញ, ជជែកគ្នា តថ្លៃទំនិញ, ឈ្លោះគ្នា, ជេរគ្នា ៗ

ហាត់និយាយ.— នៅជិតភូមិអ្នកមានផ្សារឬទេ? ផ្សារនោះយ៉ាងដូចម្ដេច? ដំបូលប្រក់អ្វី? មានជញ្ជាំងឬទេ? បណ្ដោយទទឹងផ្សារប្រវែងប្រហែលប៉ុន្មានម៉ែត្រ? នៅក្នុងផ្សារចែកជាប៉ុន្មានល្វែង? នៅល្វែងទីមួយមានលក់អ្វីខ្លះ? គេលក់ត្រីនៅកន្លែងណា? ជនជាតិណាលក់សាច់ជ្រូក? មានលក់

អ្វីទៀត ? នៅក្នុងផ្សារឮសូរយ៉ាងដូចម្តេច ? ផ្សារនោះធុំក្លិនយ៉ាងណា ? មានគេបោសលាងរាល់ថ្ងៃឬទេ ? អ្នកចូលចិត្តទៅផ្សារឬទេ ? ហេតុអ្វី ?

## បង្រៀនមើល

### ផ្សារនៅភូមិខ្ញុំ

(សៀវភៅវិជ្ជាខេមរភាសាកុមារដ្ឋានទំព័រ ១០៩ មេរៀនទី១០) ។

## សរសេរតាមសូត្រ

សូមយកសេចក្តីដែលបានបង្រៀនមើលខាងលើនេះ មកឲ្យសិស្សសរសេរតាមសូត្រផង ។ (ធ្វើដូចរបៀបមុន) ។

## អក្សរផ្ចង់

ប ប ម ហ ឋ ឡ

បំប៉ុ បំប៉ា បំបាក់បំបប បំបែក បំបែរ បំអិតបបរ

មិះ ៗ កែះ ឆ្នាំងបាយធ្លុះ ៗ

## រៀនពាក្យ – ហាត់ភាសា

### អាទិត្យទី ៣.– ភាពល្អនៃស្រុកកំណើតរបស់ខ្លួន

(សៀវភៅវិជ្ជាខេមរភាសាបរិច្ចេណដ្ឋានទំព័រ ៣៦)

នាម.– ស្រុកកំណើត, ប្រទេស, គុម្ពឫស្សី, ជ្រងស្ទួន, ផ្លូវតូច ៗ

គុណនាម.– យូរអង្វែង, ដទៃ, ល្អប្លែក, ក្រៃពេកណាស់ ៗ

កិរិយាសព្ទ.– ចេញពីស្រុកកំណើត, ត្រឡប់មកស្រុកកំណើត មកជុំ សួរសុខទុក្ខ, ស្រណោះអាឡោះអាល័យ ៗ

ហាត់ភាសា – ក្នុងរឿងនេះគេនិយាយពីអ្វី? ហេតុអ្វីបានជាបុរសនោះដើរចេញពីស្រុកកំណើត? ដល់បុរសមកវិញពួកមិត្តសំឡាញ់ធ្វើដូចម្តេចខ្លះ? កាលដែលបុរសនោះដើរទេសបានឃើញអ្វីខ្លះ? បុរសនោះអាឡោះអាល័យប្រទេសដទៃដែលល្អប្លែកឬទេ? ព្រោះអ្វីបានជាបុរសនោះត្រឡប់ជាមកអាឡោះអាល័យផ្ទះឪពុកម្តាយវិញ? ផ្ទះបែបភាពដូចម្តេច? មានដាំដើមព្រឹក្សាអ្វីខ្លះពទ្ធជុំវិញ ៗ

## ២. កាំបិតឫហារនៅវត្តភូមិបាក់ខ្នារ

សៀវភៅវិជ្ជាខេមរភាសា អាទិកដ្ឋានទំព័រ ១២៥ ។

នាម – ខេត្តពោធិ៍សាត់ ពេជ្ជ, ភ្នំក្រវ៉ាញ, ទូកញ្ញក់, រូបទេព-ប្រណម្យ, ប្រផ្នូល, ហេតុ ។

គុណនាម – បូកណា, ទំនើប, ស្អាត, កខ្វក់, អត់ឃ្លាន, សំបូណ៌ ។

កិរិយាសព្ទ – ផ្លាស់ប្តូរ, ហូតកាំបិតពីស្រោម, ប្រជុំធ្វើបុណ្យ, ផ្សងមើលប្រផ្នូល, កែហេតុ,

ហាត់ភាសា .– វត្តភូមិបាក់ខ្នារនៅខេត្តណា? នៅក្នុងវត្តនោះមានរបស់អ្វីប្លែក? ពេជ្ជនោះយ៉ាងណា? នៅក្នុងពេជ្ជនោះមានអ្វី? កាំបិតនោះរបស់អ្នកណា? ទ្រង់ទ្រាយកាំបិតនោះយ៉ាងដូចម្តេច? បើគេផ្លាស់ប្តូរទីកន្លែងកាំបិតនោះតើនឹងកើតហេតុអ្វី? បើធ្វើបុណ្យផ្សងមើលប្រផ្នូលកាំបិតនោះនៅខែណា ថ្ងៃណា? អ្នកណាដែលត្រូវហូតកាំបិតនោះចេញពីស្រោម? គេឃើញអ្វីនៅកាំបិតនោះ បានទំនាយថាល្អ - ទំនាយថាអាក្រក់?

## សរសេរតាមសូត្រ

សុំឲ្យជ្រើសរើសសេចក្ដីខាងលើនេះ មកដាក់ឲ្យសិស្សសរសេរ តាមគ្រូថាផង ។

## អក្សរផ្ចង់

ប ប ម ឋ ហ ឡ

មេមុំមូរបារី មីងម៉ែនឋាអ៊ូ កុំកំហែងគេ

## តែងសេចក្ដី

### ១- អំពីភូមិ

ឲ្យឆ្លើយតាមពាក្យចោទខាងក្រោមនេះ ៖

អ្នកនៅភូមិអ្វី ? ភូមិនោះធំឬតូច ? ទទឹងទីងបណ្ដោយមានប្រវែងប្រហែលប៉ុន្មាន ? មានផ្ទះចំនួនប៉ុន្មាន ? នៅជុំវិញភូមិនោះមានរបងឬទេ ? នៅរដូវវស្សាភូមិនោះលិចទឹកឬទេ ? នៅភូមិនោះមានដាំដើមឈើស៊ីផ្លែឬទេ ? អ្នកស្រឡាញ់ភូមិអ្នកឬទេ ? ព្រោះអ្វី ? ។

## ២- អំពីផ្សារនៅភូមិអ្នក

ថ្ងៃមួយអ្នកជូនម្ដាយអ្នកទៅផ្សារ ចូរអ្នកនិយាយរ៉ាប់រៀបអំពីដំណើរនោះ តាមរបៀបខាងក្រោមនេះ ៖

១- សេចក្ដីផ្ដើម ។ ២- ពេលវេលាដែលចេញដំណើរទៅ ។ ៣- ទៅតាមផ្លូវ ។ ៤ ដល់ទៅទីផ្សារអ្នកឃើញ-ឮអ្វីខ្លះ ? ៥- ម្ដាយ-អ្នកទិញអ្វីខ្លះ ? ៦- អ្នកសប្បាយចិត្តឬទេ ? ហេតុអ្វី ? ។

អាទិត្យទី ៤.– សុំឲ្យសួរសាចរៀនគ្រប់វិជ្ជាទាំងអស់តាំងពីអាទិត្យទី ១ ឡើងវិញ ។

---

# កុមារដ្ឋាន

## រៀនពាក្យ - ហាត់ភាសា

### អាទិត្យទី១.– ខ្លួនមនុស្ស

ពាក្យ .– ខ្លួន, ក្បាល, អវយវៈគឺដៃជើង, ក, មុខ, លលាដ៍ក្បាល, មាត់, ច្រមុះ, ភ្នែក, ថ្ងាស, ត្រចៀក, ថ្ពាល់, កំភ្លៀន

ចង្កា, រន្ធច្រមុះ, រន្ធត្រចៀក, ថ្គាម ។ ស្មា, ដើមទ្រូង, ពោះ, ខ្នង ចង្កេះ, ស្លាបប្រចៀវ, ក្លៀក ។

ភាសា.— ឲ្យយកក្មេងម្នាក់មកឈរពីមុខក្មេងទាំងឡាយក្នុងថ្នាក់ រួចគ្រូចង្អុលប្រាប់លើរូបក្មេងនោះ ពាក្យរបស់សរីរៈរាងកាយដែលត្រូវបង្រៀន ឯណាខ្លួនរបស់អ្នក ? ( នេះខ្លួនរបស់ខ្ញុំបាទ ) ។ ខ្លួនរបស់អ្នកខាងលើហៅអ្វី ? ( ក្បាល ) ។ ចុះក្រោមក្បាលហៅអ្វី ? ( ក ) ។ ចុះក្រោមកមក ? ( ដងខ្លួន ) ។ ចំណែកខ្លួនត្រង់ណាខ្លះដែលហៅអវយវៈ? ( ដៃជើង ) ។

## អាទិត្យទី ២ .— ខ្លួនមនុស្ស (ត)

ពាក្យ .— ដៃ, ដើមដៃ, កំភួនដៃ, ខ្នងដៃ, បាតដៃ, ម្រាមដៃ កែងដៃ, កដៃ, មេដៃ, ចង្អុលដៃ, ចង្អុលខ្មោចឬម្រាមកណ្ដាល, នាងដៃ, កូនដៃ ។

ជើង, ភ្លៅ, កំភួនជើង, ជើង ។ ជង្គង់, គន្ទាក់អាចម៍, ស្មង, កជើង, បាតជើង, ខ្នងជើង, កែងគោរ, ម្រាមជើង, មេជើង, កូនជើង, ម្រាមកណ្ដាល ។ ត្រគាក, កណ្ដៀតក្អម, គូថ, (ទីខាងក្រោមទាំងមូល) បាលីត្បូលោមក ។ កញ្ចឹងក, សៀតផ្កា, សក់, រោមឬលោម, ចិញ្ចើម, រោមភ្នែក, ពុកចង្កា, ពុកមាត់, ក្រចក ។

## អាទិត្យទី ៣.— ខ្លួនមនុស្ស (ត)

ពាក្យ.— សាច់ ស្បែក ឆ្អឹង, សរសៃ, ឈាម ទឹកមាត់ ទឹកភ្នែក, ខ្ទុះ ទឹកមូត្រ, ខ្យល់ដង្ហើម ដបបរ ។ ដើប ងក់ ងើត ដេក ដើរ ឈរ អង្គុយ រត់ ស្ទុះ អង្អែល ចាប់ ពាល់ កាន់ លើក ដាក់ មើល សម្លឹង ស្តាប់ ស៊ី ផឹក ស្រូប និយាយ យំ ស្រែក ទំពា ជាន់ ជះ ប្អូក ទ្រាស់ លោត ស្ទាប ប្រត់ រួញ ដោល ។

## អាទិត្យទី ៤.— ខ្លួនមនុស្ស (ត)

ពាក្យ.— សុំឲ្យរកគុណនាមមកបំពេញបទនឹងនាមដែលរៀនរួចហើយពីអាទិត្យមុនៗ ។ ក្បាលមូល ខ្លួនធំ កខ្លី ស្បែកស្តើង សាច់ទន់ សរសៃយឺត ឈាមក្រហម ទឹកមាត់ការ ....

ភាសា.- ក្បាលមនុស្សមានទ្រង់ទ្រាយដូចម្តេច ? ក្នុងខ្លួនយើង- តាំងមូលអ្វីខ្លះដែលមានសណ្ឋានវែង ? ទន់ ?

## រៀនមើលសរសេរ

អាទិត្យទី ១.— មេរៀនទី ៦ វិជ្ជាខេមរភាសាកុមារដ្ឋានទំព័រ ១២

ក្នុងអាទិត្យទី ១ នេះ ត្រូវបង្រៀនឲ្យចេះអក្សរ ១ មួយថ្ងៃទាំងគំនូរអក្សរទាំងអក្សរផ្សំស្រៈ ( បំបែក ) ឯអក្សរព្យញ្ជនៈដែលរៀនហើយ ក៏ត្រូវសរសេរទុកនៅក្ដារខៀនដរាប ដើម្បីឲ្យក្មេងឃើញជានិច្ច ។ នឹងបង្រៀនអក្សរមួយ ៗ ត្រូវរកពាក្យបណ្ដុះស្មារតីផងដូចបង្រៀនអក្សរ ឆ ឲ្យថា ឆ ឆស័ក ឆពោក សួរ ឆ ..... ។

កាលបើក្មេងចេះស្គាល់ទាំងសរសេរតួអក្សរទាំងស័ព្ទអក្សរ ទាំងបំបែបៈទីបផ្ដុំព្យញ្ជនៈបំបែកក្ដី ព្យញ្ជនៈតួទៈទក្ដីជាពាក្យពីរឬបីមាត់ ឲ្យមើល ឲ្យសរសេរចុះក្នុងសៀវភៅ ។

អាទិត្យទី ២.- មេរៀនទី ៧ (ខេមរភាសាទំព័រ ១៤)

ការចំណាំ - សុំឲ្យបង្រៀនអក្សរឬ កន្ទុយ ឫ - អក្សរឫគឺ ដតម្រួតនឹងជើងឋ

អាទិត្យទី ៣.– មេរៀនទី ៨ (ខេមរភាសាទំព័រ ១៦)

អាទិត្យទី ៤.- មេរៀនទី ៩ (សៀវភៅដដែលទំព័រ ១៩-២១)

# បរិច្ឆណាដ្ឋាន

## រៀនពាក្យ - ហាត់ភាសា

### អាទិត្យទី ១.- សិលាជាតិ

ពាក្យ .- ឲ្យគ្រូបង្ហាញព្រមទាំងប្រាប់ឈ្មោះសិលាជាតិផ្សេងៗ ដែលបានប្រមូលមកទុក ។

នាម .- ថ្ម, ថ្មដា, ថ្មកំបោរ, ថ្មក្រាត, ថ្មបាយក្រៀម, ថ្មរាន, ថ្មកៅ, ថ្មធ្មើមអណ្ដើក, ថ្មដែកក្រើង, ថ្មធ្យូង, ថ្មដីស, ថ្មត្បូង, ថ្មដៃ-រគៀម, ថ្មត្បូងពេជ្រ, ថ្មកណ្ដៀង, ថ្មត្បូងទទឹម ឬ ថ្មត្បូងក្រហម ។

គុណនាម .- ថ្មធ្ងន់, ថ្មស្រួយ, ផុយ, រឹង, ទន់, ក្ដឹ, ក្រហម, បៃតង, ក្ដិចៈទៅម្ខាង, កណ្ដៀង, ពពាល, ខ្មៅ, ព្រាត, ស្រួច, រលីប, រលង់, រលក, ធ្ងុត, ក្ដាំង, ជិត, ខ្ពី, ចាស់ ។

កិរិយា .- ជីកយក, គាស់, វាយបំបែក, ក្រាល, ឆ្វៃ, ដុស, សំលៀង, កិន, បុក, សង្កត់, រៀបចំ, ដុត, រំលាយ, បំផុស, ក្រឡឹង, ឆ្លាក់, តើង, បាក់, ប្រេះ, រលំ, របេះ ។

ភាសា .– ( ពាក្យទាំងអស់នេះត្រូវប្រើការបង្រៀន ១ អាទិត្យ )

អ្នកបានឃើញការអ្វីខ្លះដែលធ្វើដោយថ្ម? ថ្មអ្វីខ្លះដែលអ្នកស្គាល់? ថ្ម-ក្រាតសម្រាប់ធ្វើអ្វីខ្លះ? ថ្មបាយក្រៀម? ថ្មកែវ? ថ្មដា?

## អាទិត្យទី ២.– សិលា (ត)

នាម.– ថ្មដែក, ថ្មស្ពាន់, ថ្មសំណ, ថ្មស័ង្កសី, ថ្មមានសិលាឬមនោសិលា, ដីឥដ្ឋឬឥដ្ឋ, ដីខ្សាច់, លោហជាតិ, ដែក, ស្ពាន់, សំណ, នីកិល, ស័ង្កសី, មាស, ប្រាក់ ។ លាយជាតិ, ទង់ដែង, លង្ហិន, សំរិទ្ធ, ទង់ហ្វី ។

គុណនាម.– ស្វិត, ជាប់, ស្រួយ, ប្រផេះ, លឿង, ស្ងួត, ទន់, រឹង, ផុក, រលោងរលើប, ស, ណែន, ជ្រាក, ផុយ, ។

កិរិយា.– សិតដែក, រំលាយ, សប់, ចាក់ពុម្ព, បង្វរ, បំផុស, ប្រោះ, ត្រង, ដំ, ផៃ, ជ្រលក់, ស្រោម, បញ្ចាន់, ក្រឡឹង, ខាត់, កោស, រូស, សំអាតបញ្ចុះជាតិ, ដេញ, លាយ ។

## អាទិត្យទី ៣. ទី ៤.– សិលា (ត)

នាម. របស់ធ្វើដោយថ្ម, លាន, សសរ, ប្រាសាទ, ផ្នូរ, ស្តូប, ស្ពាន, ថ្មសំលៀង, បដិមាឬប្រតិមា, ជន្ទាប់, ត្បាល់កិន, ត្បាល់បុក, កំបោរ, ម្សៅ, គោល, ត្បូង, ពុម្ព, ដើង, រូបសត្វ ។

គុណនាម .– កំបោរឆាប់ ម្សៅស្ងួត, ត្បូងល្អ, គោលខ្ពស់, ត្បាល់កិនបេច, ថ្មសំលៀងផុយ, បដិមាសម, ស្កូបស្តុកស្តក, ជន្ទាប់មូលៗ

កិរិយា .– សង់ប្រាសាទ, បោះគោករ, ដាប់ថ្ម, ក្រឡឹងជន្ទាប់, លាយកំបោរ, ច្រោះម្សៅ, បុក, កិន, ដាំត្បូង, ឆ្លាក់រូប, ប៉ាន់រូប, ផ្ដិតពុម្ព រៀបថ្ម ។

## រៀនមើល

អាទិត្យទី ១ .–

មេរៀនទី ១_ ក្រុមជាងសង់ផ្ទះ (វិជ្ជាខេមរៈទំព័រ ៣៤)

ពាក្យពន្យល់ ._ក្រុមជាង គឺជាងច្រើននាក់ ធ្វើការជាមួយគ្នា ។ គ្រឹះ = តួផ្ទះ ; សិតផ្ទាន = ឈូសសំអាត ។

អានពាក្យ . រៀប (កំប្រុះឡើងកប) លាប (កុំប្រុះឡើងលៀប)

មេរៀនទី ២.– សិលា (វត្តស្វាយព្រាយន៍ បរិវត្ត ទំព័រ៧៦)

ពាក្យពន្យល់ ._ សិលា = ថ្មចាំងឡាយ ។ វិញ្ញាណ ការដឹង-ដោយប៉ះពាល់

អានពាក្យ.– វិញ្ញាណ ថាវិញញាណ ៗ ការ កុំច្រឡំនឹង-វៀវ)

មេរៀនទី ៣. ប្រយោជន៍នៃថ្ម (វត្ថុស្វាធ្យាយន៍ ទំព័រ ៧៧)

ពាក្យពន្យល់. គួត = ត្រដុសគ្នា ៗ កំបិត (ឲ្យកែជាកាំបិត) គ្រឿងប្រើកាប់ឬកាត់ ៗ រហែងថ្ម = ទីមានថ្មច្រើន ៗ

អាទិត្យ ២.–

មេរៀនទី ១. ថ្មកំបោរ (វត្ថុស្វាធ្យាយន៍ ទំព័រ ៧៩

មេរៀនទី ២. អំពីប្រដាប់ប្រើការធ្វើស្រែចំការ (វិជ្ជាខេមរ. បរិ. ទំព័រ ២១

មេរៀនទី ៣.– ត្បូងថ្ម ប្រេងកាត (វត្ថុស្វាធ្យាយន៍ ទំព័រ ៨០)

អាទិត្យទី៣.–

មេរៀនទី ១ .– អំបិល (វត្ថុស្វាធ្យាយន៍ ទំព័រ ៨២)

មេរៀនទី ២ .. វត្ថុនៅភូមិខ្ញុំ (វិជ្ជាខេមរ, បរិ, ទំព័រ ៦២ ដល់ប្រណាំងគ្នាលេង)

មេរៀនទី ៣ វត្តនៅភូមិខ្ញុំ (ត) ដល់ចប់

អាទិត្យទី ៤.–

មេរៀនទី ១.– ដុំមានដម្លៃ (វគ្គស្វាធ្យាយន៍ ទំព័រ ៨៤)

មេរៀនទី ២.– លោហធាតុ (សៀវភៅដដែលទំព័រ ៨៦)

មេរៀនទី ៣.– ដែក សៀវភៅដដែលទំព័រ ៨៨

## សរសេរតាមសូត្រ

អាទិត្យទី ១.–

១– ក្រុមជាងសង់ផ្ទះ (វិជ្ជាខេមរ បរិវ ទំព័រ ៣៤)

ពាក្យប្រើញឹកញយ.– ការ, អ្នក, គ្រឹះ ឥដ្ឋ, ក្តារ, បង្ហូរ ទ្វារ, ល្អ, ៗ

បទក្នុងវេយ្យាករណ៍ . សង់ សង:, ចាក់ ចាក:, ធ្លាក់ និង ទឹក ៗ (') បន្តក់ – បន្តក់ដាក់លើពាក្យសព្ទខ្លីដែលកើតពីស្រៈ អ និង ស្រៈ អា លើអក្សរ ង, ញ, ត, ន, ប, ល, ស, ៗ

២– សិលា (វគ្គស្វាធ្យាយទំព័រ ៧៦ សង្កាត់ខាងដើម)

ពាក្យប្រើញឹកញយ._ (សិលា, ថ្ម, សត្វ, ប្ដូរ, អាហារ, ខុស)

៣– សិលា (ត) ដល់ចប់

ពាក្យពន្យល់._ រស = ជាតិក្លិន ឬរស់ មានជីវិត ដូនទីងចួនៗ

អាទិត្យទី ២.–

១.– អំពីប្រដាប់ប្រដាធ្វើស្រែចំការ (មេរៀនមើល)

២.– ប្រយោជន៍នៃថ្ម (វគ្គសា. បរិច្ឆ. ទំព័រ ៧៧) សង្កាត់ដើម

៣.– ប្រយោជន៍នៃថ្ម (ត) ដល់ចប់

អាទិត្យទី ៣ ទី ៤

១– ថ្មកំបោរ (វគ្គស្វា. បរិច្ឆ. ទំព័រ ៧៩ ដល់ផុតកំបោរ)

២– ថ្មកំបោរ (ត) ដល់ចប់

កែពាក្យឲ្យត្រឹមត្រូវ.– ខុស ឲ្យសរសេរ ខុសៈ អិដឲ្យ សរសេរតដ្ឋ

៣ –វត្តនៅភូមិខ្ញុំ (រៀងមើល - តាំងពីនៅខាងត្បូងព្រះវិហារ ..... ដលគ្នាលេង)

កែដំរូវ.– ត្បូង (ថ្បូង) រិហារ (វីហារ): ទូកង (ទូកងរ) បុណ្យ-(បុណ្យ)

## តែងសេចក្ដី

### អាទិត្យទី ១.–

ចូរបំពេញត្រង់កន្លែងចន្លោះ ដែលពាក្យគួរប្រើ ៗ ដើម្បីនឹងសង់ផ្ទះគេរក..... ជាច្រើននាក់ ៗ ជាងខ្លះជីក..... នឹងជាងដាំសសរខ្លះ.....ឈើធ្វើគ្រឿងខាងលើគឺ..... ខ្លះឈូស .....ធ្វើជាកំពល ធ្វើជាជញ្ជាំង ធ្វើជាទ្វារនឹងបង្អួច ៗ ផ្ទះសង់-ស្រេចហើយជាងគំនូរ.....ថ្នាំ ជាងដែកដាក់..... ៗ

### អាទិត្យទី ២.–

សូមឲ្យតែងសេចក្ដីទុកចន្លោះ ឲ្យបំពេញពីគ្រឿងប្រដាប់ធ្វើស្រែចំការ ៗ

### អាទិត្យទី ៣ – ទី ៤

១– សូមឲ្យតែងសេចក្ដីទុកចន្លោះ នឹងឲ្យបំពេញអំពីជាងរៀប-ឥដ្ឋជញ្ជាំង ៗ

២– អំពីរបស់ធ្វើដោយថ្ម

# [illegible]

## នព្វន្ត

### អាទិត្យទី១ –    លេខគុណ

បើខ្ញុំទិញដងប៉ាកកា ៣ មួយថ្លៃ៥សេន នោះខ្ញុំនឹងចេញថ្លៃឲ្យគេយ៉ាងដូច្នេះ ។

៥សេន + ៥សេន + ៥សេន= ១៥សេន

គឺថាថ្លៃចំនួនទាំង៣ដងនេះស្មើគ្នាទាំងអស់ ឬខ្ញុំត្រូវធ្វើលេខគុណដូច្នេះវិញ ។ ខ្ញុំសរសេរ ៥ សេន × ៣=១៥សេន ។ ៥ ជាលេខតាំង ដែលខ្ញុំថាដដែលៗឡើងវិញបីដង ។ ៣ ជាមេគុណ ។ លេខតាំងគឺចំនួនដែលគេហៅដដែលៗឡើងវិញ ។ មេគុណគឺចំនួនប៉ុន្មានដងដែលគេថាដដែលៗឡើងវិញ ។ ផលគឺជាចំនួនសរុបលេខគុណនោះ ។

លេខតាំង × មេគុណ= ផល

សេចក្ដីសំខាន់.— ការដែលមានប្រយោជន៍ជាទីបំផុតក្នុងលេខគុណត្រូវឲ្យរៀនចេះចាំស្ទាត់នៃមេលេខគុណ ។

**វិធីហាត់គិតមាត់ទទេ** .– ១– សូមសាចស្រៀនមេលេខគុណ តាំងពីមេពីរឡើងវិញ រហូតមកដល់មេដប់ ។ ២– ពែងមួយថ្លៃ ៨ សេន ពែង ៦ ថ្លៃប៉ុន្មាន ? ។ ពែង ៨ ថ្លៃប៉ុន្មាន ? ។ ពែង ៤ ថ្លៃប៉ុន្មាន ? ។ ពែង ៩ ថ្លៃប៉ុន្មាន ? ។ ពែង ៧ ថ្លៃប៉ុន្មាន ? ។ ពែង ១០ ថ្លៃប៉ុន្មាន ? ។ ខ្ញុំរាប់តើត្រូវជាប៉ុន្មាន ម្ជុល ៥ ប្រាំបួនដង ឡេវអាវ ៨ ប្រាំបួនដង កន្ត្រៃ ៤ ប្រាំបួនដង ហុងអម្បោះ ៩ ដប់ដង ? ។

**វិធីហាត់សរសេរ**.– ១– អ្នកជំនួញតុ ទូ តាំងម្នាក់ទិញកៅអី ៣៧ ថ្លៃ ៤ រៀលមួយ អ្នកនោះលក់ទាំងអស់ទៅចំណេញបាន ៣២ រៀល តើថ្លៃលក់កៅអីទាំងអស់នោះប៉ុន្មាន ? ។ ២– សួនមួយពាង ២ ជ្រុង បណ្ដោយ ១៨ ម៉ែត្រ ទទឹង ១២ ម៉ែត្រ ជុំវិញសួននោះគេធ្វើរបងថ្លៃ ១៥ សេន ១ ម៉ែត្រ តើថ្លៃរបងនោះប៉ុន្មានរៀល ? ។

២– មេគុណមានលេខតែមួយខ្ទង់

ជាងម្នាក់មានប្រាក់ខែ ២៣ រៀលក្នុង ១ ខែ បានប្រាក់ប៉ុន្មានបើជាងនោះធ្វើការបាន ៣ ខែ ។ ក្នុង ៣ ខែ ជាងនោះចំណេញ ២៣ រៀល ៣ ដង ឬ ២៣ រ.×៣ ។

និងធ្វើលេខគុណបែបដូច្នេះគេត្រូវដាក់បែបនេះ ៖

$$\begin{array}{r} ២៣ \\ + \ ៣ \\ \hline ៦៩ \end{array}$$

គេថា ៣ បីដង ៩ ខ្ញុំសរសេរ ៩ រួចខ្ញុំថា ៣ ពីរដង ៦ ខ្ញុំសរសេរ ៦ ខាងក្រោម ផលលេខនេះគឺ ៦៩ រៀល ៗ វិធីហាត់មាត់ទទេ ;- ចូរធ្វើលេខដូចមានដាក់ភាយមកខាងក្រោមនេះ :

៣៣រុ × ៤ + ៦៥រុ - ... ៦៤ស + ៨ : ៨ស = ......

៥៤ក + ៧ - ៧៥ក = ៗ ៧៤ម × ៣ ៥៧៩ម ... ៗ

បំណោទ = អ្នកជំនួញសត្វពាហនៈម្នាក់បានលក់ក្របី ៤ ថ្លៃ ៤២ រៀលមួយ ឃើញចំណេញទាំងអស់ ៤៨ រៀលតើថ្លៃដើមក្របីទាំង ៤ នេះប៉ុន្មាន ?.

– អ្នកជំនួញសំពត់ម្នាក់បានទទួលសំពត់ ៥ ផាប់ ប្រវែង ១២ ម៉ែត្រមួយផាប់ និង ៧ ដុំទៀតប្រវែង ១០ ម៉ែត្រមួយដុំ ៗ អ្នកជំនួញនោះបានទទួលសំពត់ប៉ុន្មានម៉ែត្រ ? ៗ

## លេខគុណមានត្រាទុក

ខ្ញុំបានជួលមនុស្ស ៣ នាក់ធ្វើការ ហើយខ្ញុំឲ្យឈ្នួល ៣៥ សេនម្នាក់ ៗ ៗ តើខ្ញុំត្រូវឲ្យឈ្នួលប៉ុន្មានទាំង ៣ នាក់នេះ ? ៗ

ខ្ញុំសរសេរយ៉ាងនេះ :

  ៣៥
× ៣
―――
១០៥

ខ្ញុំថា ៣ ប្រាំដង ១៥ ឬ ៥ សេន ខ្ញុំសរសេរ ៥ នឹងប្រាក់កាក់មួយដប់សេន ឬ ១០ សេនមួយដង ហេតុនេះខ្ញុំត្រូវត្រាទុកមួយ ៗ កាក់បី ៗ ដង ៩ កាក់ ហើយនឹងត្រាទុក ១ នោះត្រូវជា ១០ ខ្ញុំសរសេរដប់គឺ ១០៥ សេន ខ្ញុំត្រូវឲ្យឈ្នួលទាំងអស់ ១០៥ សេន ៗ

វិធីហាត់សរសេរ ៖– ហេតុអ្វីនៅក្នុងលេខគុណមានត្រាទុក គេត្រូវផ្ដើមគុណពីខាងស្ដាំ មិនឲ្យផ្ដើមគុណពីឆ្វេង? លេខត្រាទុកមានហួសពីលេខ ៨ ឬទេ? ហេតុអ្វី? អ្នកត្រូវរកយ៉ាងដូចម្ដេចឲ្យបានឆាប់ឃើញ ថ្លៃគោ ៣ នឹមនឹងថ្លៃគោ ២ នឹម បើគោមួយថ្លៃ ៤៧ រៀល ? ៗ

វិធីហាត់សរសេរ ៖ ១ – ចូរធ្វើលេខដូចមានខាងក្រោមនេះ ៖

៥៦រ × ៦=    ៧៥រ × ៧=    ៩៨រ × ៨=

៣៩២ម × ៣=    ៧២៤ម × ៥=    ៦៥៩ល + ៤=

## អាទិត្យ ២.– លេខចែក ( ផលហារមានលេខតែមួយតួ )

ខ្ញុំចង់ចែកស្លាបប៉ាកកា ២៤ ឲ្យសិស្ស ៤ នាក់ តើម្នាក់ៗ ត្រូវបានប៉ុន្មាន? ៗ រកចំណែកម្នាក់ ៗ នោះត្រូវយកចំនួន ២៤ មកចែកនឹង ៤ ៗ យើងគិតថា ក្នុង ២៤ តើមាន ៤ ប៉ុន្មានដង ៗ ថាមាន ៤ ប្រាំមួយដង, ដូច្នេះសិស្សម្នាក់ៗត្រូវ

បានស្វាបប៉ាកកា ៦ ។ គេសរសេរលេខយ៉ាងនេះ ២៤: ៤=៦ ហើយ ដើម្បីនឹងធ្វើលេខចែកយ៉ាងនេះដោយងាយ នោះត្រូវរៀនមេលេខឲ្យស្ទាត់ ។

សូមមើលហើយបង្រៀនតាមសៀវភៅក្បួនទន្ទេញទំព័រទី ៤៣ ដល់ ៤៧ ។

## អាទិត្យទី ៣ -- ១ ថ្លៃទិញវត្ថុសរុប

ឧបមា: មាខ្ញុំលក់គោបក្រយានមួយ ថ្លៃ ៧៣៥៛ គាត់បានចំណេញទាំងអស់ ១៣៥៛ តើគោបក្រយាននោះទិញមកថ្លៃប៉ុន្មាន ? ។

នឹងរកថ្លៃទិញវត្ថុសរុបធ្វើអ្វីមួយ ត្រូវយកប្រាក់ចំណេញទៅកាត់ថ្លៃលក់ចេញ គឺ:

៧៣៥៛ - ១៣៥៛ (លក់ - ចំណេញ)

ឃើញថាគោបក្រយាននោះទិញមកថ្លៃ ៦០០៛ ។

វិធីហាត់គិតមាត់ទទេ.— អ្នកស្រីម្នាក់លក់ចៀមមួយថ្លៃ ២៨៣ រៀល ហើយបានចំណេញ ៥០ រៀល តើចៀមនោះទិញមកថ្លៃប៉ុន្មាន ។

ស្រីម្នាក់លក់ក្រមា ៥ ថ្លៃ ៤៣ រៀល ហើយបានចំណេញ ១៣ រៀល តើក្រមាទាំងអស់ទិញមកថ្លៃប៉ុន្មាន ?

វិធីហាត់សរសេរ.— ចំណោទ .— ឪពុកខ្ញុំលក់មួក ៥ បានថ្លៃ ១៣៣

រៀលមួកមួយ ហើយបានចំណេញតាំងអស់ ១២៥រ ។ តើមួកតាំងអស់ទិញមកថ្លៃប៉ុន្មាន ? ។

## ២.– ថ្លៃទិញរបស់ពីមួយ ៗ

ឧបមា = ឈ្មួញម្នាក់លក់ទូ ៣ ថ្លៃតាំងអស់ ៣៥០រ ហើយបានចំណេញ ៥០រ, តើថ្លៃដើមទូមួយទិញមកថ្លៃប៉ុន្មាន ? ។

មុននឹងរកថ្លៃដើមទូនិមួយ ៗ ត្រូវរកថ្លៃទូតាំង ៣ សិន ទើបយកថ្លៃដើមទូតាំងអស់មកចែកនឹងចំនួនទូនោះគឺ :

ថ្លៃដើមទូតាំង ៣ គឺ (ថ្លៃលក់ - ចំណេញ)

៣៥០រ,– ៥០រ,= ៣០០រ

ថ្លៃដើមទូមួយ : (ថ្លៃដើម: ចំនួនរបស់ដែលទិញមក )

៣០០រ,: ៣ = ១០០រ

ឆ្លើយថាទូនិមួយ ៗ ទិញមកថ្លៃ ១០០រ

វិធីហាត់គិតមាត់ទទេ .– ១.– ស្រីម្នាក់លក់មាន់ ៣ ថ្លៃ ៣៣ រៀល ហើយបានចំណេញ ៩ រៀល, តើមាន់មួយទិញមកថ្លៃប៉ុន្មាន ? ។

២ – ចិនម្នាក់លក់ស្រាទំពាំងបាយជូរ ៥ ដបថ្លៃ៥៥រ ហើយចំណេញ ១៥ រៀល តើស្រាទំពាំងបាយជូរមួយដបទិញមកថ្លៃប៉ុន្មាន ? ។

វិធីហាត់សរសេរ.- ចំណោទ - យួនម្នាក់លក់មួកស្លឹក ៣ឡូ ថ្លៃ ២២៦ រៀល បានចំណេញ ៣៦ រៀល ៗ តើមួកនិមួយ ៗ ទិញជាមកថ្លៃប៉ុន្មាន ?

## រង្វាស់រង្វាល់

អាទិត្យទី ១ .- អំពីក្រដាសប្រាក់សំរាប់ចាយនៅប្រទេសឥណ្ឌូចិន ៖ ប្រាក់ក្រដាសមួយរៀល, ៥ រៀល ៗ

សូមយកប្រាក់ក្រដាសមកបង្រៀន ហើយឲ្យបានច្រើនយ៉ាងផង ក្រដាសប្រាក់ជាន់ចាស់ នឹងក្រដាសប្រាក់ជាន់ថ្មី ៗ បង្ហាញក្រដាសប្រាក់រៀលឲ្យសិស្សមើល នេះក្រដាសប្រាក់ ១ រៀល មានសរសេរលេខចំនួន ១ រៀលជាប់នៅនេះផង ដើម្បីកុំឲ្យច្រឡំ មានពណ៌ ក្បាច់រចនាក្ដឹស្អាតហើយមានរូបយួនប្រុសស្រីទៀតផង ៗ ក្រដាសប្រាក់ ១ រៀលជាន់ថ្មី ខុសពីក្រដាសប្រាក់ ១ រៀលជាន់ចាស់ដោយទំហំនឹងគំនូរ ៗ ក្រដាសប្រាក់ប្រាំរៀលជាន់ថ្មីមានរូបប្រាសាទខុសអំពីក្រដាសចាស់ដែលមានរូបក្ងោក ៗល ៗ ក្រដាសប្រាក់ស្រាល គេយកទៅណាមកណាបាន

ដោយងាយដល់អ្នកជំនួញទាំងឡាយ ប៉ុន្តែត្រូវប្រយ័ត្នក្រដាសប្រាក់ក្លែងក្លាយ គេចំណាំទឹកលេខទឹកសាច់ក្រដាស ឬទឹកពណ៌ក្រដាសៗលៗ

ហាត់គិតមាត់ទទេ .— ក្រៅពីប្រាក់រៀល ឬប្រាក់កាក់មានប្រាក់អ្វីខ្លះសំរាប់ចាយនៅស្រុកយើង ? ប្រាក់ក្រដាសមួយរៀលពណ៌ដូចម្តេច ? មានរូបអ្វី ? ប្រាក់ក្រដាសមួយរៀល នឹងប្រាំរៀលដូចគ្នាឬ-ទេ ៗ ខុសគ្នានឹងអ្វី ! ឯងមើលពីចម្ងាយស្គាល់ជាក្រដាស ១ រៀល ៥ រៀលឬទេ ៗ ពីព្រោះអ្វីបានជាគេយកក្រដាសធ្វើជាប្រាក់ចាយ ៗ ក្នុងប្រាក់ក្រដាស ១ រៀល នឹងប្រាក់សាច់ ១ រៀលប្រាក់ណាមានដម្លៃជាង ៗ ពីព្រោះអ្វីបានជាមានដម្លៃដូចគ្នា ៗ ក្នុងប្រាក់ក្រដាស ១ រៀលមានប៉ុន្មានកាក់ ៗលៗ

ហាត់គិតនឹងក្តារខ្មៀន.— ត្រូវជាប៉ុន្មាន ២៥ នឹង ៣៨ រៀល ១០៧ នឹង ៨០ រៀល ៗ ប្រាក់ក្រដាស ៥ រៀល ៣ សន្លឹកនឹងក្រដាស ១ រៀល ២៦ សន្លឹកត្រូវជាប៉ុន្មានរៀល ៗលៗ

អាទិត្យទី ២ .— ប្រាក់ក្រដាស ២០ រៀល ១០០ រៀល ៗ

សូមធ្វើដូចអាទិត្យទី ១ ខាងលើនេះ ពន្យល់សិស្សអំពីពណ៌ទំហំក្រដាសប្រាក់ម្ភៃរៀលនឹង ១០០ រៀលឲ្យស្គាល់ប្រាក់ក្លែង ៗ

ហាត់គិតមាត់ទទេ.- ក្រដាសប្រាក់មានប៉ុន្មានយ៉ាង ? ក្រដាសប្រាក់អ្វីខ្លះ ? ក្រដាសប្រាក់ទាំងនេះដូចគ្នាឬទេ ? ខុសគ្នានឹងអ្វី ? ។ល។

ហាត់គិតនឹងក្ដារខៀន. ត្រូវជាប៉ុន្មានរៀល ២៧ រៀលនឹង ៣៣ រៀល ។ ១៧៥រ, នឹង ១៤០ រៀល ។ ១៨០រ, នឹង ១០០ រៀល ។ល។ នៅសល់ប៉ុន្មាន ២៨០រ, កាត់ ១៩០ រៀលចេញ ។ ៣៥០ រៀលដក ១៨៥ រៀលចេញ ។ ខ្ចីគេម្ដង ១៥០ រៀល ម្ដងទៀត ៩៥ រៀល តើ-ជំពាក់គេទាំងអស់ប៉ុន្មានរៀល ។ បងខ្ញុំជំពាក់គេ ២៨០ រៀល យក ១៩៥ រៀលទៅសងគេ តើបងខ្ញុំនៅជំពាក់គេប៉ុន្មានរៀលទៀត ។ល។

ហាត់សរសេរ. ចូរធ្វើលេខដូចមានខាងក្រោមនេះ :

២០១ + ១៩៣រ,= ...រៀល ។ ៣៥០រ, + ១៥៥រ,...រៀល។

៣៦៧រ, - ២៧២រ,= . . រៀល ។ ៤៥២រ, – ២០៧រ, ... រៀល។

២- បងចៅនាងទិញចង្កៀង ១ ថ្លៃ ១៦ រៀល ទិញម៉ាស៊ីនច្រៀង ១ ថ្លៃ ៥៤ រៀល រួចបានឲ្យក្រដាស ១០០ រៀលមួយសន្លឹកទៅអ្នកលក់ ។ ត្រូវថែមឲ្យមកវិញ...រៀល ។

## អាទិត្យទី ៣.– អំពីប្រាក់ណែន

សូមរកប្រាក់ណែនមកឲ្យសិស្សមើល បើគ្មានត្រូវគូរនៅក្ដារខៀន ប្រាក់ណែនកង់ដូចស្លាបឥតមានក្បាលគ៊ីទេ ងាយនឹងធ្វើណាស់ ក្នុង១ ណែនមានទម្ងន់ ១៦ រៀល ហេតុនេះបានជាគេចាយ ១៦ រៀល ។ ឥឡូវនេះរាជការលែងឲ្យចាយប្រាក់ណែននឹងប្រាក់ជាន់ចាស់ហើយ ព្រោះប្រាក់ទាំងនេះមនុស្សខូចកាចធ្វើក្លែងក្លាយបានដោយងាយណាស់ៗ

ហាត់សរសេរ.– មាខ្ញុំលក់ស្រូវបាន ៤ ណែន លក់ពោតបាន. ១៤០ រៀល មាខ្ញុំបានប្រាក់ទាំងអស់ .....រៀល ។

---

## មជ្ឈិមដ្ឋានទី ១

**គណិត**

### អាទិត្យទី ១.– ចំនួនពីមួយពាន់ ទៅដល់មួយម៉ឺន

ឯរបៀបរាប់ចំនួនពីមួយ ១.០០០ ទៅដល់ ១០.០០០ ក៏ដូចជារាប់ ចំនួនពី ១០០ ដល់ ១០០០ ដែរ គេរាប់ថាមួយពាន់មួយ មួយពាន់ពីរ

មួយពាន់បី តទៀតៗ ទៅដល់១.០៩៩ ទើបគេថាមួយពាន់មួយរយ រួចទើបគេរាប់ពីមួយពាន់មួយរយតទៅ មួយពាន់ពីររយ មួយពាន់បីរយ រហូតតទៅដល់មួយម៉ឺន (១០.០០០) ។ ឯចំនួនពី ១ ដល់ ៩ លេខមានតែមួយតួគឺចំនួនរាយឬខ្ទង់រាយ ។ ពី ១០ ដល់ ៩៩ មានលេខពីរតួគឺខ្ទង់ដប់ ។ ១១០ ដល់ ៩៩៩ មានលេខបីតួគឺខ្ទង់រាយ ។ ពី ១.០០០ ដល់ ៩៩៩៩ មានលេខបួនតួគឺខ្ទង់ពាន់ ។ ១០.០០០ ដល់ ៩៩.៩៩៩ មានលេខប្រាំតួគឺខ្ទង់ម៉ឺន ។

ដូចមានតារាងដាក់ឈ្មោះខ្ទង់ខាងក្រោមស្រាប់

| ខ្ទង់ម៉ឺន | ខ្ទង់ពាន់ | ខ្ទង់រយ | ខ្ទង់ដប់ | ខ្ទង់រាយ |
|---|---|---|---|---|
| ៩ | ៤ | ៧ | ៩ | ២ |

របៀបរៀនមើល .— នឹងរៀនមើលលេខនេះ គេចាប់មើលពីឆ្វេងទៅស្តាំ ឧបមាដូចជា ៩៤៧៩២ គេមើលថាប្រាំបួនម៉ឺនបួនពាន់ប្រាំពីររយកៅសិបពីរ ពីព្រោះ៩នៅខ្ទង់ម៉ឺន រួចគេមើលលេខបន្ទាប់ ៤ ពាន់ ពីព្រោះលេខ ៤ នៅក្នុងខ្ទង់ពាន់ហើយមើលលេខតមកទៀត ៧ រយ ពីព្រោះលេខ

៧ នៅខ្ទង់រយ ហើយគេមើលមកទៀតទៅសិប ពីព្រោះលេខ ៩ នៅខ្ទង់សិប ហើយគេមើលលេខចុងក្រោយបំផុតជាពីរ ពីព្រោះលេខពីរនៅខ្ទង់ទឹងឬកាយ ។

របៀបរៀនសរសេរ .– ទឹងសរសេរចំនួនដល់ម៉ឺននេះ ក៏ដូចជាគេសរសេរចំនួនពី ១ ដល់ ១.០០០ ដែរ គេចាប់សរសេរពីឆ្វេងទៅស្ដាំ គឺចាប់ពីខ្ទង់ម៉ឺន មកខ្ទង់ពាន់ មកខ្ទង់រយ មកខ្ទង់សិប រួចមកខ្ទង់ទឹង ប៉ុន្តែបើចំនួនណា មួយខ្វះ កង់ខ្ទង់ម៉ឺនក្ដី ខ្ទង់ពាន់ក្ដី ខ្ទង់រយក្ដី ។ល។ គេដាក់លេខសូន្យជំនួស ឧបមាដូចជា ១.៤០៩១ ។

ហាត់គិតមាត់ទទេ .– ហៅចំនួនឲ្យសិស្សសរសេរនៅលើក្ដារខៀន ១៥.៩៧២ ។ ១៩.៥៦៣ ។ ៧.៨៩៧ ។ល។ ឲ្យសិស្សមើលសូត្រចំនួនខាងក្រោមនេះ ៩៥.៧៥១ ។ ២.៣៥៦ ។ ៣៧.៤៦១ ។ ៩៥.៦៨៩ ចូរឲ្យសិស្សរាប់បន្ថែមមួយរយៗ ។ ពី ១០០ ទៅដល់ ១០.០០០ ។

វិធីហាត់គិតនឹងក្ដារឆ្នួន .– ត្រូវជាប៉ុន្មាន

១៥.០០០ នឹង ២៣.៤០០ ។ ១៣.០០ នឹង ៧០.០០០ ។ ៤៩.០០០ នឹង ៦០.០០០ ។ ១៣.០០០ ដក ៥.០០០ ចេញ ។ ២– ខ្ញុំគា

៣៤.០០០ នឹង ៣ ០០០ គឺ ៤ នឹង ៣ បានជា ៣៧.០០០ ។ ខំគិតទុក បែបដូចគ្នាទៅទៀត ។ ៣៦.០០០ នឹង ២.០០០ ។ ៧៣.០០០ នឹង ៥.០០០ ។ ៦៤.០០ ។ ដក ៣.០០០ ចេញ ។

វិធីហាត់សរសេរបំណោទ . – ក្នុងការសង់ផ្ទះមួយគេបានដឹកឥដ្ឋ ៥ រទេះ ក្នុងមួយរទេះមានឥដ្ឋ ១.០០០ ដុំរួចបានប្រើឥដ្ឋនោះអស់ ៣០០០ ដុំតើគេនៅសល់ឥដ្ឋប៉ុន្មានដុំទៀត ។

២- អ្នកម៉ៅការម្នាក់បានទិញដីមួយកន្លែងថ្លៃ ១.៥៤០ រៀល អ្នកនោះបានសង់ផ្ទះមួយនៅនាដីនោះថ្លៃ ៥.៤៨៧ រៀល ដល់លក់ផ្ទះទៅវិញបានថ្លៃ ៨.៩០០ រៀល តើអ្នកនោះបានបំណេញប៉ុន្មាន ?

អាទិត្យទី២– លេខគុណនឹង ១០ - ១០០ - ១.០០០

ចានមួយថ្លៃ ៥ រៀល បើចាន ១០ ថ្លៃប៉ុន្មាន ។ យើងដឹងថាចានមួយថ្លៃ ៥ រៀល បើចាន ១០ យ៉ាងដូច្នេះថ្លៃ ៥ រៀលដប់ដងទៅទៀត គឺថា ៥ ដប់ដងត្រូវជា ៥០ ។ ក៏ប៉ុន្តែយើងគុណលេខចំនួនប៉ុន្មាន ៗ ក្តីនឹង១០ ១០០-១.០០០ នេះគេមិនចាំបាច់ធ្វើលេខដូចធម្មតាទេ គ្រាន់តែថែមសូន្យមួយនៅខាងស្តាំចំនួននោះ បើគុណនឹង ១០ ។ សូន្យពីរបើគុណនឹង១០០ ។ សូន្យបី បើគុណនឹង ១.០០០ ។

អាទិត្យទី១._ លេខចែកនឹង ១០-១០០-១.០០០ កែវដប់ថ្លៃ៦០ រៀល តើកែវមួយថ្លៃប៉ុន្មាន ? យើងដឹងថាកែវដប់ថ្លៃ៦០ រៀល បើកែវមួយថ្លៃតិចជាងគឺយ៉ាងដូច្នេះ ៦០៛ : ១០ = ៦ រៀល ។ ក៏ប៉ុន្តែនឹងចែកលេខចំនួនប៉ុន្មាន ៗ ក៏ដោយនឹង ១០ - ១០០ - ១.០០០ នេះគេមិនចាំបាច់ធ្វើលេខដូចធម្មតាទេ គេគ្រាន់តែបន្ថយកណ្ដក់សញ្ញាពីខាងស្ដាំទៅខាងឆ្វេងមួយខ្ទង់ សម្រាប់ចែកនឹង១០ ។ ពីរខ្ទង់សម្រាប់ចែកនឹង១០០ បីខ្ទង់សំរាប់ចែកនឹង១.០០០ ។ល។ ឧបមាដូចជាលេខ ៨.៩២០ ចែកនឹង ១០ ត្រូវបាន ៨៩២,០ ។ ៨.៩២០ ចែកនឹង១០០ ត្រូវបាន៨៩,២០ ៨.៩២០ ចែកនឹង១០០០ ត្រូវបាន ៨,៩២០ ។ល។

**មេរៀនឲ្យចាំមាត់** បើកាលណាត្រូវចែកចំនួនអ្វីមួយ ៗ នឹង១០ ១០០-១.០០០ នោះ គេមិនបាច់ធ្វើលេខទេ គេត្រូវតែបន្ថយកណ្ដក់សញ្ញាពីស្ដាំទៅឆ្វេងមួយខ្ទង់ ពីរខ្ទង់ បីខ្ទង់ ។ល។

## រង្វាស់រង្វាល់

**អាទិត្យទី ១.— ដេស៊ីម៉ែត្រ**

សូមពិនិត្យម៉ែត្រឲ្យឃើញថាម៉ែត្រនោះចែកជា ១០ កំណាត់ស្មើគ្នា

មួយកំណាត់ហៅថាមួយដេស៊ីម៉ែត្រ ឬមួយភាគដប់នៃម៉ែត្រ មួយដេស៊ីម៉ែត្រ គឺមួយភាគដប់តូចជាងម៉ែត្រ ។

មួយម៉ែត្រមាន ១០ ដេស៊ីម៉ែត្រ គេសរសេរកាត់ ដ.ម. ឧបមាដូចជា ៦៥ ម = ៦៥០ ដ.ម. ។ ៩០ ដ.ម. = ៩ ម ឧបមាវាស់បណ្ដោយវត្ថុអ្វីមួយ គេឃើញ ២ ម៉ែត្រ ៧ ដេស៊ីម៉ែត្រ ឬ ២ ម៉ែត្រនឹង ៧ ភាគដប់ម៉ែត គេសរសេរ ២ ម ៧ ។

គេវាស់បណ្ដោយវត្ថុមួយទៀត ឃើញ ៤ ដេស៊ីម៉ែត្រ ភាគដប់ម៉ែត្រ គេសរសេរ ០,៤០, ៧ នឹង ០ ៤ ហៅថាចំនួនបែងភាគគត់ ៧ ភាគដប់នឹង ៤ ភាគដប់ ហៅចំណែកបែងភាគគត់ពីមួយចំនួនណាគ្មានចំណែកបែងភាគគត់ហៅថាចំនួនដុំ ចំនួនបែងភាគគត់តែងមានចំណែកបែងភាគគត់ពីមួយជាប ។

ពាក្យសួរ -១- មួយម៉ែត្រមានប៉ុន្មានដេស៊ីម៉ែត្រ ?

២- មួយដេស៊ីម៉ែត្រ គឺជាភាគប៉ុន្មានពីម៉ែត្រ ?

៣- យ៉ាងដូចម្ដេចហៅថាចំនួនដុំ

៤- យ៉ាងដូចម្ដេចហៅថាចំនួនបែងភាគគត់ ?

៥- ចំនួនបែងភាគគត់មានប៉ុន្មានចំណែក ?

៦– ក្នុងចំនួនបែងភាគគត់ លេខខ្ទង់ដើមខាងស្ដាំមកណ្ដាក់សញ្ញាហៅអ្វី

វិធីហាត់សរសេរ.– ចូររកចំនួនខាងក្រោមនេះ៖

៣២ម+៥៧ម=...ដ.ម. ។ ១២០ម : ១០=...ដម ។

១៨៧ ដ.ម.×៤៩=...ដ.ម. ។ ២៤ដ.ម.×=...ដ.ម.=

..ដ.ម.។១៣ដ.ម.×៣០ម· ៥ដ.ម.=...ម...ដ.ម. ។

## អាទិត្យទី ២.– ដេស៊ីលីត្រ

រង្វាល់ចំណុះចំនួនគត់គឺលីត្រ រង្វាល់លីត្រមួយ យើងអាចវាល់ចំណុះដបស្រាទំពាំងបាយជូរមួយបានឬទេ ? ដបទឹកក្រូចមួយបានឬទេ ? ហេតុអ្វីបានជាវាល់មិនបាន ។ ដើម្បីនឹងវាស់ប្រវែងខ្លី ៗ ជាងម៉ែត្រនោះគេបានក្រិតចែកម៉ែត្រនោះជាដេស៊ីម៉ែត្រ បើយ៉ាងដូច្នេះគឺថាដូចគ្នាដែរ ទឹងវាល់ចំណុះវត្ថុអ្វីនិមួយៗ ដែលតូចជាងលីត្រនោះគេបានធ្វើរង្វាល់តូចជាងលីត្រ គឺដេស៊ីលីត្រ ។ គេសរសេរកាត់ ១ ដ.ល. ។ ដេស៊ីលីត្រគឺ ១ ភាគ ដប់តូចជាងលីត្រ ហេតុដូច្នេះមួយលីត្រមានដប់ដេស៊ីលីត្រ (១០ ដ.ល.) ។

សូមត្រួតត្រាផ្ទៀងមើល ទឹងលីត្រហើយទឹងដេស៊ីលីត្រ រាល់ទឹងដេស៊ីលីត្រហើយដាក់ទៅក្នុងលីត្រ ។

**វិធីហាត់គិតមាត់ទទេ** :— មានប៉ុន្មានដេស៊ីលីត្រក្នុង២ លីត្រ ? ៥ លីត្រ ? ៣លីត្រ ? ។ ១លីត្រកន្លះ ? ៣លីត្រកន្លះ ? ។ ដបមួយមានចំណុះស្រាមួយលីត្រ គេបានលក់អស់៥ ដ-ល-នៅសល់ស្រាប៉ុន្មានដេស៊ីលីត្រទៀតក្នុងដបនោះ ? ។ រួចគេលក់មួងទៀតអស់ ៣ដ-ល- ក្នុងដបស្រានោះនៅប៉ុន្មានដេស៊ីលីត្រទៀត? ដែលទឹងបំពេញដបមួយមានចំណុះ មួយលីត្រគេត្រូវដាក់ថែមប៉ុន្មានទៀតទៅក្នុងដបនោះ បើសិនជានៅក្នុងដបនោះមាន២ ដ.ល-?។ ៥ដ-ល.។ ៨ដ-ល-។ ១ដ-ល ។ ៧ ដ-ល-។ ៦ដ-ល-។ ៩ដ ល-។ ២ដ-ល-។ ៤ ដ-ល-។

បំណោទ.— ផុចិនមួយមានស្រាចំណុះ៥ល៨ គេដងស្រានោះមុនដំបូង២ល- រួច១ល៦ ហើយគេចាក់ចូលទៅវិញ១ល៩។ មានស្រាប៉ុន្មានលីត្រទៀតនៅក្នុងផុចិននោះ ?។

## អាទិត្យទី ៣.— ដេស៊ីក្រាម

សូមបង្រៀនដូចរបៀបខាងលើនេះ ។

# មធ្យមដ្ឋាន នឹង អាទិកដ្ឋាន

## ធរណីមាតសាស្ត្រ

អាទិត្យទី១ = អំពីមុម . មុមផ្សេង ៗ –

ប្រដាប់បង្រៀន .– ប្រដាប់ឈាន ( កំប៉ា )

អត្ថន័យ ·– បន្ទាត់ ១. ក. នឹងបន្ទាត់ ១. គ· ដែលចេញពី




ចំណុចតែមួយបង្កើតជាមុម
មួយគឺមុម ក. ១. គ. ។
បន្ទាត់ ១. ក. នឹង ១. គ· ជាជ្រុង
របស់មុម ។ ចំណុច ១. ជាកំពូលរបស់មុម ។

មុមផ្សេង ៗ ១ មុមកែង – មុមកែងកើតពីជ្រុងសំយុងត្រង់លើគ្នា ។

២ – មុមស្រួច – តូចជាងមុមកែង ។

៣ – មុមធ្លាយ – ធំជាងមុមកែង ។

សេចក្ដីរំលឹក ៖– មុមតូចធំមិនមែនស្រេចនឹងប្រវែងជ្រុងឡើយ គឺស្រេចនឹងវង្វះជ្រុងដែលឃ្លាតពីគ្នា ។ សូមគ្រូយកប្រដាប់ឈានពីរ ទំហំខុសគ្នាមកធ្វើពិសោធន៍ឲ្យសិស្សមើល ។ ហើយឲ្យសិស្សនេះ ហៅឈ្មោះមុមដោយហៅអក្សរកំពូលនៅកណ្ដាលជានិច្ច ។

អាទិត្យទី ២.– បួនជ្រុងស្មើ– បន្ទាត់អឌ្ឍបាត (មេឌិយ៉ាន) បន្ទាត់ទ្រូង (ឌីយ៉ាគោណាល់)

ប្រដាប់បង្រៀន ៖ ក្រដាសបួនជ្រុងស្មើដើម្បីបត់បង្ហាញសិស្សឲ្យឃើញថា ៖

ក.– ក្នុងបួនជ្រុងស្មើបន្ទាត់អឌ្ឍបាតនឹងបន្ទាត់ទ្រូងកាត់គ្នាចំពាក់កណ្ដាល ។

ខ.– ហើយមុមដែលកើតឡើងជាមុមកែង ។

អាទិត្យទី៣.– បរិវេណនៃបួនជ្រុងស្មើ ។

អាទិត្យទី៤.– រកប្រវែងជ្រុងមួយក្នុងបួនជ្រុងស្មើ ។

សូមគ្រូចាត់ចែងបង្រៀនផងចុះ ។

# កុមារដ្ឋាន

## នព្វន្ត

### មេរៀនទី ១.– ចំនួនពី ២០ ដល់ ២៩

ការរៀនរាប់ - រៀនមើល - រៀនសរសេរចំនួន

របស់សំរាប់បង្រៀន .– ចង្កឹះចាប់ - ចង្កឹះរាយ ប្រាក់កាក់ ១០ សេន ២០ សេន នឹងលុយសេន

របៀបបង្រៀន .–

១ - បញ្ជាក់អំពីចំនួន ពី ១ ដល់ ១៩

២– រៀនចំនួន ២០- លើកចង្កឹះ ១៩ បង្ហាញសិស្សហើយថែម ចង្កឹះ ១ទៀត ពន្យល់សិស្សថាត្រូវជា ២០

៣– ពន្យល់របៀបសរសេរចំនួន ២០- សរសេរឲ្យសិស្សមើល នៅលើក្ដារខៀន - ឲ្យសិស្សសរសេរនៅក្ដារខៀន - ឲ្យសិស្សសរសេរ នៅលើក្ដារឆ្នួន

៤– ពន្យល់របៀបរៀនរាប់ - រៀនមើល - រៀនសរសេរចំនួន ២១
២២ - ២៣ --- ដល់ ២៩ តាមរបៀបខាងលើនេះ ។

៥– ការហាត់បញ្ជាក់អំពីរបៀបរៀនរាប់ - រៀនមើល រៀនសរ.
សេរចំនួនពី ១៩ ដល់ ២៩ ។

៦– ការហាត់គិតមាត់ទទេ ឲ្យសិស្សរាប់បន្ថែម ២ - ៣ - ៤ - ៥
ពី ១ ដល់ ២៩ រាប់បន្ថយមកវិញ ។

មេរៀនទី ២ .– ចំនួនដល់ ២៩ - រៀនធ្វើលេខបូកឥតគ្រាទុក ។

របៀបបង្រៀន .–

១– ការហាត់គិតមាត់ទទេ - ឲ្យសិស្សរាប់បង្កើន - គ្រាប់គ្រួសបន្ថែម
២ៗ - ៣ៗ - ៤ៗ - ៥ៗ ពី ១ ដល់ ២៩ ។

២– ពន្យល់របៀបធ្វើលេខបូកនៅលើក្ដារខៀន

៣ – ឲ្យសិស្សធ្វើលេខបូកនៅលើក្ដារខៀន

៤– ការហាត់បញ្ជាក់នៅលើក្ដារឆ្នួន

មេរៀនទី ៣ .– ចំនួនដល់ ២៩ - រៀនធ្វើលេខសងឥតគ្រាទុក
មើលតាមរបៀបខាងលើនេះ

មេរៀនទី ៤.– ចំនួនដល់ ២៩ - រៀនមេលេខគុណនឹងមេ២ ទ្វេគុណ ។

មេរៀនទី ៥. ចំនួនដល់ ២៩ រៀនចែកចំនួនជាពីរ - ពាក់កណ្ដាល ។

មេរៀនទី ៦.– សាបញ្ជាក់អំពីវិជ្ជាដែលបានរៀនក្នុងខែនេះ ។

## រង្វាស់រង្វាល់

មេរៀនទី ១.– អំពីរង្វាស់ដេស៊ីម៉ែត្រ (ដ.ម)

របស់សំរាប់បង្រៀន.– ម៉ែត្របត់ - ដេស៊ីម៉ែត្រគោះ - បន្ទះប្រវែង ១ ដ.ម. - ៣ ដ.ម. - ៤ ដ.ម. ។

របៀបបង្រៀន.–

១ សួរសាកបញ្ជាក់អំពីម៉ែត្រ ។

២ នាំសិស្សពិនិត្យមើលម៉ែត្រ ឃើញចែកជា ១០ ចំណែកស្មើគ្នា

៣– គ្រូគូសគំនូសប្រវែង ១ ដ.ម. នៅលើក្ដារខៀន ។

៤– នាំសិស្សពិនិត្យមើលប្រវែង ១ ដ.ម. ។

៥- ឲ្យសិស្សគូសគំនូសប្រវែង ១ ដ.ម. នៅលើក្ដារខៀនហើយវាស់បញ្ជាក់

៦. នាំសិស្សហាត់ស្ទាវបណ្ដាយរបស់ដែលមានប្រវែង២-៣-៤-៥ ដេស៊ីម៉ែត្រ ។

៧- ការហាត់គិតមាត់ទទេ គិតផ្ទេរពីម៉ែត្រទៅដេស៊ីម៉ែត្រ ។ ពីដេស៊ីម៉ែត្រទៅជាម៉ែត្រ ។

មេរៀនទី២-អំពីរង្វាស់ សន្ទីម៉ែត្រ

មេរៀនទី៣-អំពីរង្វាស់ ដេស៊ីម៉ែត្រក្វាះ

មេរៀនទី៤-សាបញ្ជាក់ឡើងវិញ

សុំមើលតារាងរបៀបធ្វើជូនជាគំរូខាងលើស្រាប់ ។

ការសំខាន់ក្នុងការបង្រៀនរង្វាស់-រង្វាល់នៅថ្នាក់កុមារដ្ឋាន គឺឲ្យសិស្សស្គាល់ប្រវែង ចំណុះ ទម្ងន់នៃរបស់ដែលសិស្សបានពិនិត្យដោយបានឃើញបានលើកហើយឲ្យបេះស្ទានដោយមើល ដោយលើក ពុំចាំវាស់វាល់ឬថ្លឹង ។ ហេតុនេះសុំលោកគ្រូនាំសិស្សហាត់ស្ទាន ហាត់ប្រើប្រាស់រង្វាស់រង្វាល់ដែលបានបង្រៀនឲ្យបានច្រើនបំផុត ។

# បរិច្ឆេទលំដាប់

## គណិត

មេរៀនទី ១.- ចំនួនពី ២០០ ដល់ ៣០០

ការរៀនរាប់ - រៀនមើល - រៀនសរសេរចំនួន

មេរៀនទី ២.- ចំនួនដល់ ៣០០ - រៀនធ្វើលេខបូកនឹង-

លេខសង

មេរៀនទី ៣.- ចំនួនពី ៣០០ ដល់ ៤០០

ការរៀនរាប់ - រៀនមើល - រៀនសរសេរចំនួន

មេរៀនទី ៤.- រៀនមេលេខគុណ (មេ ៣ - ៤ - ៥).

មេរៀនទី ៥.- ចំនួនពី ៤០០ ដល់ ៥០០

ការរៀនរាប់ - រៀនមើល - រៀនសរសេរចំនួន

មេរៀនទី ៦.- ចំនួនដល់ ៥០០

រៀនគុណចំនួននឹង ៣ - ៤ - ៥

មេរៀនទី ៣.– ចំនួនដល់ ៥០០

រៀនចែកចំនួនជា ៣ - ៤ - ៥ ៗ

សុំធ្វើតាមរបៀបរៀបចំដូចជាគំរូក្នុងទស្សនាវដ្តីលេខ ២ មុននេះ សព្វគ្រប់ស្រាប់ហើយ ទាំងរបៀបបង្រៀន រាប់មើល - សរសេរចំនួន នឹងរបៀបបង្រៀនធ្វើលេខ ៗ

## វង្វាស់ - វង្វាល់

មេរៀនទី ១.– អំពីវង្វាស់ ដេកាម៉ែត្រ

របស់សំរាប់បង្រៀន.– ម៉ែត្រ - ច្រវាក់ប្រវែង ១ ដេកាម៉ែត្រ

របៀបបង្រៀន.– នាំសិស្សចេញទៅក្រៅថ្នាក់រៀន ៗ មានកាន់ក្តារខ្មៀននឹងដីស ៗ

១– នាំសិស្សវាស់ប្រវែង ១០ ម៉ែត្រ

២– ប្រាប់សិស្សថាប្រវែង ១០ម គេហៅថា ១ ដេកាម៉ែត្រសរសេរកាត់ (១ ដា.ម.)

៣– នាំសិស្សពិនិត្យមើលប្រវែង ១០ម ឲ្យស្គាល់ច្បាស់ ដើម្បីឲ្យចេះស្មានប្រវែង ១ ដា. ម.

៤– ការហាត់ស្ទាន - នាំសិស្សស្ទានបណ្តោយផ្លូវ ទីធ្លាដែល-មានប្រវែង ១ដ.ម. - ២ដ.ម. - ៣ដ.ម. . . . ហើយវាស់បញ្ជាក់នឹងប្រវាក់ដេកាម៉ែត្រ ។

៥– ការហាត់គិតមាត់ទទេ - នាំសិស្សហាត់គិតផ្ទេរពីដេកាម៉ែត្រទៅជាម៉ែត្រ - ពីម៉ែត្រទៅជាដេកាម៉ែត្រ ។

៦- ការហាត់ដោយសរសេរ - សំដែងការហាត់ចាំងពីរបែបនេះឲ្យសព្វគ្រប់ផង ។

## មេរៀនទី ២ .– អំពីប្រវាក់ ១ ដេកាម៉ែត្រ .

របៀបសំរាប់បង្រៀន .– ប្រវាក់ ១ដេកាម៉ែត្រ នឹងម៉ែត្របត់ ។

## របៀបបង្រៀន .– (ចេញទៅក្រៅកន្លែងរៀន)

១– នាំសិស្សវាស់ប្រវែង ១០ម · សួរសាកអំពីដេកាម៉ែត្រ តាមមេរៀនថ្ងៃមុន ។

២– នាំសិស្សវាស់ប្រវែង ១០ម នោះនឹងប្រវាក់ដេកាម៉ែត្រ ហើយពន្យល់សិស្សថាប្រវាក់នេះមានប្រវែង ១០ម៉ែត្រ

៣– នាំសិស្សពិនិត្យមើលប្រវាក់នោះ (គ្រប់ ១ម៉ែត្រមានប៉ុន្មានកំណាត់ - មានអ្វីជាសំគាល់ · គ្រប់ ៥ម មានអ្វីជាសំគាល់)

៤- ការហាត់ស្ទាន

៥– ការហាត់គិតមាត់ទទេ

៦– ការហាត់ដោយសរសេរនៅក្នុងសៀវភៅ សុំតែងការហាត់ទាំងនោះឲ្យសព្វគ្រប់ផង ។

មេរៀនទី ៣.– អំពីរង្វាល់ដេកាលីត្រ ។

មេរៀនទី ៤.– អំពីទម្ងន់ ១ ដេកាក្រាម ។

សុំមើលតាមរបៀបជាគំរូខាងលើនេះហើយ សូមតែងការហាត់ឲ្យបានសព្វគ្រប់ផង ។

---

## មជ្ឈិមដ្ឋានទី ២

### វិទ្យាសាស្ត្រ

មេរៀនក្នុងខែ .–

អាទិត្យទី ១ .– អំពីគ្រឿងប្រដាប់សំរាប់ដកដង្ហើម ។ អំពីការដកដង្ហើម ។

អាទិត្យទី ២ .- អំពីគ្រឿងប្រដាប់សំរាប់ឈាមរត់ ។ អំពីការឈាមរត់ក្នុងខ្លួន ។ - អំពីការបញ្ចេញវត្ថុសៅហ្មង ។

អាទិត្យទី៣.- អំពីពួកសត្វ ។ អំពីថនិកសត្វ ។ល។

អាទិត្យទី៤ - សូមសាបម្រៀនឡើងវិញ ។

មេរៀនខាងលើនេះ សឹងមានក្នុងសៀវភៅវត្ថុស្វាធ្យាយន៍ ថ្នាក់អាចិកជូនខ្លះហើយ ខ្លះទៀតដែលគ្មានក្នុងសៀវភៅនេះសូមលោកតែងផងចុះ តាមមេរៀនជាគំរូខាងក្រោមនេះ ។

មេរៀនជាគំរូ.- អំពីការឈាមរត់ ។

ប្រដាប់សំរាប់បង្រៀន.- ឈាមស្រស់ បេះដូងជ្រូក ម្ជុល បំពង់ កៅស៊ូ ផ្ទាំងគំរូឈាមរត់ក្នុងខ្លួន ។ល។

ការពិនិត្យ.- ចាំសិស្សស្ទាបបេះដូង - ជីពចរ រាប់ចំនួនជីពចរក្នុងមួយមីនុត បានពី ៧០ ទៅដល់ ៨០ នៅរូបមនុស្សគ្មានជម្ងឺ ។

មេរៀន.- ដូចម្ដេចហៅថាឈាម (ឈាមជាវត្ថុរាវមានព័ណក្រហមខាប់ ហើយស្អិតផង ក្លិនឆ្អាប ប្រៃ ។ល។ ឈាមនៅកន្លែងណា ៗ កាលណាយើងយកម្ជុលទៅចាក់សាច់យើង នៅកន្លែងណាក៏ដោយយើង

នឹងឃើញឈាមចេញមកពីក្នុងសាច់យើង មានពណ៌ក្រហមឆាំ ៗ ដូច្នេះនៅក្នុងខ្លួនយើងទាំងមូល មានឈាមគ្រប់កន្លែង ៗ យើងមើលកដៃយើងនឹងឃើញនៅក្រោមស្បែក មានសរសៃរវាម ហើយមានពណ៌ខៀវបន្តិច នោះគឺជាបំពង់ដែលឈាមរត់ពាសពេញក្នុងខ្លួនយើង ។ល។

អំពីបេះដូង .— បើយើងដាក់ដៃយើងទៅលើទ្រូងខាងឆ្វេងយើងនឹងដឹងបេះដូងយើងកំរើក ៗ បេះដូងជាអ្វី? (បេះដូងជាគ្រឿងប្រដាប់មួយសំខាន់ណាស់ សំរាប់ធ្វើឲ្យឈាមរត់ក្នុងខ្លួនយើង) ។ ចុះបើបេះដូងមិនដើរតើយើងនឹងបានសេចក្តីយ៉ាងណា? (យើងនឹងស្លាប់ជាមិនខាន) ។ តើបេះដូងនោះប៉ុនណាទៅ? (វាមិនធំប៉ុន្មានទេ ប្រហែលប៉ុនកំកួនដៃ មានរាងដូចជាក្តិបដូង (សូមបង្ហាញបេះដូងជ្រូក ឬគំនូររូបបេះដូងឲ្យសិស្សឃើញផង) ។

សរសៃឈាមរត់ .- សរសៃឈាមរត់តើដូចម្តេច? (សរសៃឈាមរត់បែករសេមរសាម ពាសពេញទាំងខ្លួន ដូចជាមែកឈើដែរ មានតាំងពីធំទៅតូច ដែលនាំឲ្យចេញចូលក្នុងបេះដូង' ។

ឈាមមានប្រយោជន៍អ្វី .- ឈាមសំរាប់ទ្រទ្រង់ជីវិត នឹងគ្រប់ចំណែកនៃខ្លួនយើង តាមខ្យល់អាកាសបំរុងធាតុដែលយើងដក

ដង្ហើមតាមសួតៗ ឈាមនេះហើយអាចបង់បញ្ចេញវត្ថុសៅហ្មង ពីក្នុងខ្លួនយើងទៅក្រៅបាន ។

ឈាមកើតមកពីអ្វី .— ឈាម កើតមកពីអាហារដែលយើងបរិ-ភោគរាល់ថ្ងៃ ។ល។

របៀបសង្ខេប .— ឈាមស្រស់ជាវត្ថុរាវមានពណ៌ក្រហម ខាប់ មានក្លិនឆ្អាបហើយប្រៃបន្តិច ។ ឈាមគេមានពណ៌ក្រហមជាំ ។

ឈាមរត់ក្នុងខ្លួនយើងឥតមានឈប់សោះឡើយតាមសរសៃឈាមៗបេះដូងជាសាច់ដុំមួយ មានប្រយោជន៍បូមនៅខាងក្នុង សំរាប់ត្រងឈាមឲ្យស្អាត ហើយធ្វើឲ្យឈាមរត់ចេញ–ចូលពាសពេញក្នុងខ្លួនយើង ។ កាលណាបេះដូងកំរើកម្តង ៗ ឈាមរត់ចេញពីបេះដូងទៅពាសពេញទាំងខ្លួនតាមសរសៃ ហើយវិលចូលទៅក្នុងបេះដូងវិញ តាមសរសៃមួយបែបទៀត ។ ឈាមជាគ្រឿងប្រដាប់យ៉ាង ប្រសើរណាស់ សំរាប់ទ្រទ្រង់ជីវិតឲ្យរស់នៅ ។

ពាក្យសួរក្នុងមេរៀន .— ឈាមជាវត្ថុដូចម្តេចៗ ឈាមរត់ក្នុងខ្លួនយើងដូចម្តេច ។ ដូចម្តេចហៅថាបេះដូង ។ ហេតុអ្វីបានជាបេះដូងកំរើកជានិច្ច ។ ឈាមរត់ក្នុងខ្លួនយើងតាមអ្វី ។ ឈាមក្នុងខ្លួនយើងមានប្រយោជន៍ឬទេ ។

## អនាម័យ

មេរៀនក្នុងខែ:

អាទិត្យទី១ .— *ការរក្សាគ្រឿងវិញ្ញាណ ។ ការថែរក្សាភ្នែក-ត្រចៀក ។*

អាទិត្យទី២ និងទី៣ .— *ការថែរក្សាសរសៃវិញ្ញាណ ។ល។*

អាទិត្យទី៤ .— *សាបង្រៀនមេរៀនក្នុងខែឡើងវិញ ។*

*សូមបង្រៀនតាមសៀវភៅវិធីបង្ការោគគាំពារ តាំងពីទំព័រទី១៦ រហូតដល់ទំព័រទី២០។ មេរៀនឯទៀតខ្ញុំបានធ្វើមេរៀនជាគំរូជូនពីឆ្នាំមុនរួចអស់ហើយ សូមមើលទស្សនាវដ្ដីលេខ ៣ ឆ្នាំទី២ ត្រង់ទំព័រ ៧៨ ទៅដល់ទំព័រ ៨១ ។*

---

### អាទិកង្គន

## វិត្តស្វាធ្យាយន៍

អាទិត្យទី១ .— *អំពីសត្វព្រៃ*

គ្រូត្រូវរកផ្ទាំងគំនូរដែលមានរូបសត្វព្រៃ បង្ហាញសិស្សដូចជាខ្លាធំ-ខ្លារខិន ។ល។

ខ្លួនខ្លា.- នាំសិស្សពិនិត្យមើលរូបរាងសត្វខ្លា ។ ឲ្យសិស្សសង្កេតមើលខ្លួនខ្លា ។ រាងដូចម្ដេច ។ ឲ្យសង្កេតមើលក្បាលមាត់ ។

ក្រចកខ្លា.- ខ្លាមានជើងប៉ុន្មាន? សត្វដែលមានជើងបួនហៅសត្វអ្វី? នៅចុងជើងមានអ្វី? ក្រចកខ្លាមានសណ្ឋានបែបណា ។ (កោងខ្ទបចុះក្រោមស្រួចលឹបចូលលូតចេញបានតាមចិត្ត) ឯក្រចកនេះសម្រាប់អ្វី? (ចាប់ក្រញាំសត្វជាអាហារ) ធ្មេញខ្លាស្រួចហើយវែង ។ ចង្កូមវាវែងហើយមុតណាស់ៗ ខ្លួនខ្លារាងវែងទន់ហើយរហ័សណាស់ ។

អាហារខ្លា.- ខ្លាស៊ីអ្វី? វាចាប់សត្វអ្វីខ្លះ យកមកបរិភោគ? សត្វដែលបរិភោគសាច់នៅគេហៅសត្វអ្វី? (មំសាហារសត្វ) ខ្លានៅជិតមនុស្សឬទេ? វាច្រើននៅឯណា? ខ្លាកាចឬស្លូត? គេបាញ់យកស្បែកវាធ្វើអ្វី? ក្រចកវាគេធ្វើអ្វី?

## អាទិត្យទី ២.- អំពីពស់

ប្រដាប់សម្រាប់បង្រៀន.- គ្រូត្រូវរកពស់ត្រាំស្រាដាក់កែវយកមកបង្ហាញសិស្ស បើគ្មានដូច្នេះទេត្រូវរកផ្ទាំងគំនូរដែលមានរូបខ្លះវង្គសត្វៗ

នាំសិស្សសង្កេតមើលរូបរាងពស់ដូចម្ដេច ? (វែងដូចអន្ទង់)គេឃើញមានអ្វីនៅពាសពេញខ្លួនវា ? (មានស្រកា)

មេរៀនសង្ខេប.— ឧរង្គសត្វគឺជាសត្វមានឈាមត្រជាក់ខ្លួនសត្វនេះគ្មានរោមទឹងស្លាបទេ មានតែស្រកាពាសពេញជុំវិញខ្លួនហើយលូនលើដីៗ ពស់គ្មានជើងទេ ។ ពស់ខ្លះដូចជាពស់សម្លាប់កង្កែបដែលជាពស់គ្មានពិសទេ ។ ខ្លះមានពិសបិកស្លាប់ដូចជាពស់វែកជាដើម ។ ពស់ថ្លាន់គ្មានពិសទេ ប៉ុន្តែវាអាចរិតមនុស្សស្លាប់បានដោយវាធំហើយវាខ្លាំងផងៗ ពស់សកតាមរដូវ ។

## អាទិត្យទី៣.— ការបរបាញ់

ប្រដាប់សម្រាប់បង្រៀន.— នេសាទុបករណ៍ខ្លះដូចជាស្នា-ធ្នូ-ព្រួញ-មួល-អន្ទប់ ជង់- បន្ទឹង ។ល។

ពាក្យសួរ.— គេចាប់សត្វឬសម្លាប់សត្វដោយវិធីបែបណាខ្លះ ? (ចាក់-បាញ់ឬដាក់ថ្នាំបំពុល) សត្វអ្វីខ្លះ ដែលគេបំផ្លាញដោយវាជាសត្វចង្រៃ ? សត្វអ្វីខ្លះដែលគេបាញ់ឬដាក់អន្ទាក់យកសាច់ជាអាហារ ។ គេបាញ់ខ្លាយកអ្វីវា ? ដំរីយកអ្វី ។ សត្វណាខ្លះ ដែលគេបាញ់យកស្បែក ។ យកស្នែងៗ យកធ្មឹងៗយកមកធ្វើថ្នាំ ។

## អាទិត្យទី៤- អំពីនេសាទ

នេសាទឧបករណ៍- អួន មង សំណាញ់ អញ្ចាង ឆ្នុក គន អន្ទ្រុត លប ទ្រូ សៃយ៉ឺន ។ល។

ការនេសាទត្រីមានប្រយោជន៍ច្រើននៅប្រទេសឥណ្ឌូចិន គេនេ-សាទត្រីនៅទន្លេនិងសមុទ្រ ។

តាមមាត់សមុទ្រស្រុកតុងកឹង ស្រុកកូសាំងស៊ីនហើយនិងស្រុកខ្មែរ គេនេសាទត្រីបានច្រើនណាស់ ។

នៅនគរខ្មែរកន្លែងជាប់ត្រីធំបំផុត គេច្រើនធ្វើនៅទន្លេសាប ក្នុងមួយឆ្នាំៗដល់ខែមិនា មានចិន យួន ចាមហើយនិងខ្មែរច្រើនទៅនៅមាត់បឹងទន្លេសាប តាមធម្មតាគេធ្វើផ្ទះខ្ពស់ៗនៅក្នុងទឹកនៅជិតផ្ទះនោះគេធ្វើកនសំពបហាលត្រីផង ។

របៀបធ្វើការនេសាទ គេច្រើនធ្វើតាមបែបបូរាណ នៅក្នុងទឹកគេបោះបង្គោលឈើតូចៗជាច្រើនប្រយោជន៍និងខាំងកំទេចកំទីដែលអណ្តែតទឹកមកហើយនិងឲ្យត្រីមកនៅផង គេយកព្រួលឫស្សីទៅព័ទ្ធជុំវិញកន្លែងនោះរួចហើយអ្នកនេសាទដងត្រីនោះនិងជួង អ្នកនេសាទខ្លះប្រើមង ។

ក្នុងមួយថ្ងៃគេលើកមួយដងឬពីរដង មុននឹងលើកគេវាយទឹកដេញត្រីនឹងបន្ទះឫស្សី ។

តាមស្ទឹងអ្នកនេសាទច្រើនដាក់ឆ្នស់ធ្វើនឹងឫស្សីរាំងនៅមាត់ស្ទឹង - គេដាក់មែកឈើជាច្រើននៅកន្លែងណាដែលគេធ្វើនេសាទ ប្រយោជន៍ឲ្យត្រីមកនៅរួចស្រេចហើយទើបគេរាំងឆ្នស់ខាងក្រោម ឯឆ្នស់នោះបីចំណែក ចំណែកមួយគេហៅថាព្រួលធ្វើនឹងបន្ទោះឫស្សី ចំណែកមួយទៀតហៅថាប្រា គឺជាប្រដាប់ចាប់ត្រីចំហនៅជិតព្រួល ចំណែកទីបីហៅថាសិងនៅជិតប្រា គឺជាកន្លែងដាក់ត្រីដល់រដូវទឹកស្រកត្រីចុះតាមទឹកមកលុះទើសនឹងព្រួលវាហែលចូលទៅក្នុងប្រា ។

ឯត្រីដែលចាប់បានមក គេយកមកធ្វើត្រីងៀតត្រីឆ្អើរ,ប្រហុក, ទឹកត្រី,ផ្អក,ខ្លាញ់នឹងការផង ។

គេនាំត្រីងៀតទៅលក់ច្រើននៅស្រុក (សិង្ហបុរី) សង្គប៉ូ ហើយនឹងប្រទេសចិន

## វិធីបង្ការរោគ

អាទិត្យទី ១ .— ជម្ងឺក្អក .— ជម្ងឺក្អកមានពីរយ៉ាង ៖ ជម្ងឺក្អក

មានខ្ទុះហូរចេញនឹងជម្ងឺភ្នែកឡើងបាយ ។ ជម្ងឺនេះឆ្លងឬទេ ? ដូច្នេះត្រូវធ្វើម្ដេច ? (កុំឲ្យមមង់ឬរុយរោម) កុំយកដៃឬកំណាត់កខ្វក់ជូតភ្នែក ។

ជម្ងឺភ្នែកមានខ្ទុះហូរចេញមានលក្ខណៈយ៉ាងណា ត្របកភ្នែកហើម កែវភ្នែកក្រហម មានខ្ទុះហូរចេញជានិច្ច ភ្នែកឡើងងាសមើលអ្វីមិនច្បាស់ ជម្ងឺភ្នែកឡើងបាយមានលក្ខណៈបែបណា បែបគ្នានឹងជម្ងឺភ្នែកមានខ្ទុះដែរតែនៅខាងក្នុងត្របកភ្នែកមានឡើងបាយដុំតូចៗ ។

ដុំនេះទុកយូរទៅ នឹងកើតជាដំបៅដោយរោមភ្នែកជូតៗ ត្រូវដាក់ថ្នាំបណ្ដាយ ពុំនោះទេភ្នែកនឹងខូច ។

## អាទិត្យទី ២.– ការថែរក្សាភ្នែក

កុំពាល់ភ្នែកនឹងម្រាមដៃ - ត្រូវជៀសវាងកុំឲ្យប៉ះទង្គិចនឹងអ្វី កុំឲ្យត្រូវខ្យល់ ធូលីឬផ្សែង ។ ត្រូវខ្ចបពន្លឺចាំងខ្លាំងដោយកុំមើលថ្ងៃ ។ ត្រូវដាក់សៀវភៅមើលចម្ងាយ ៣០ ស. ម. ពីភ្នែក ។ បើភ្នែកឡើងក្រហមត្រូវលាងនឹងទឹកក្ដៅ បើពុំជាត្រូវទៅរកពេទ្យមើលកុំបណ្ដោយ ។

**មេរៀនសង្ខេប.–** ជម្ងឺភ្នែកនេះឈឺយឺតណាស់ ប៉ុន្តែគង់នឹងបណ្ដាលឲ្យខ្វាំងបានដូចជាជម្ងឺភ្នែកដែលមានខ្ទុះហូរចេញនោះដែរ មុនដំបូងភ្នែកចាញ់ពន្លឺថ្ងៃណាស់ចេះតែហូរទឹកភ្នែក ខាងត្របកមានឡើង

បាយដុំតូច ៗ ដូចជាគ្រាប់បាយគេមើលឃើញគ្រាប់បាយនោះជាក់ច្បាស់ ដោយត្រឡប់ត្របកភ្នែកខាងក្នុងចេញមកខាងក្រៅ ដល់ត្របកភ្នែកត្រឡប់ចូលទៅក្នុងវិញ រោមភ្នែកដុតគ្រាប់បាយនោះហើយកកើតជា-ដំបៅ ដល់ក្រោយមកភ្នែកឡើងពណ៌ប្រផេះហើយក៏មើលលែងឃើញសោះ ៗ ហេតុដូច្នេះតែកាលណាមានជម្ងឺឈឺភ្នែកនេះហើយត្រូវរួសរាន់រកថ្នាំថែទាំជាប្រញាប់ ឯថ្នាំទៀតត្រូវរកតែថ្នាំណាដែលធ្វើដោយមានក្បួនខ្នាតត្រឹមត្រូវ ចូរកុំទុកភ្នែកឲ្យឈឺហួសការហើយទើបទៅរកគ្រូពេទ្យឲ្យ;មើលនោះ ៗ

## អាទិត្យទី ៣.— ការថែរក្សាត្រចៀក

ត្រូវជូតស្លឹកត្រចៀកឲ្យស្អាតជានិច្ច បើទឹកចូលត្រចៀកត្រូវប្រញាប់គ្វារចេញឲ្យអស់តែទុកនឹងបណ្ដាល ឲ្យកើតអំបៅអំបែកខូចត្រចៀកកុំគ្វារត្រចៀក នឹង របស់រឹងឬស្រួច ខ្លាច ជ្រុលដៃនាំឲ្យធ្លាយក្រដាសត្រចៀកឬកោសដាច់សាច់ខាងក្នុង ត្រូវប្រើសំឡីក្នុងការគ្វារត្រចៀក;ដោយជ្រមទឹកអប់បន្តិច ៗ ផង (ទឹកកូឡូញ)

## អាទិត្យទី៤ រៀនសាដើមឡើងវិញ

# មជ្ឈិមដ្ឋានទី ១

## វត្ថស្វាធ្យាយន៍

### អាទិត្យទី ១.— ថនិកសត្វ

ប្រដាប់សម្រាប់បង្រៀន.— គ្រូត្រូវរកផ្ទាំងគំនូររូបថនិកសត្វ មកបង្ហាញសិស្សមានរូប ឆ្កែ ឆ្មា សេះ ដំរី ជ្រូក គោ ជាដើម ។

លក្ខណៈនៃ ថនិកសត្វ.— ចូរពិនិត្យមើលសត្វគោមានអ្វីពេញដុំវិញខ្លួនវា ? (រោម) វាមិនពងដូចជាសត្វស្លាបទេ វាកើតកូនតែម្ដង ។ វាចិញ្ចឹមកូនវានឹងអ្វី ។ សត្វអ្វីខ្លះដែលរោមពេញដុំវិញខ្លួន ហើយចិញ្ចឹមកូននឹងទឹកដោះ ។ ពួកសត្វនេះជាពួកថនិកសត្វ (ថនៈ ឬថនា: ដោះ) ថនិកសត្វជាសត្វឈាមក្ដៅ គឺចំហាយឈាមមិនផ្លាស់ប្ដូរបានឡើយ ។

មានថនិកសត្វខ្លះនៅក្នុងទឹកដូចជាផ្សោតនឹងត្រីសមុទ្រមួយយ៉ាងដែលបាកំងហៅថា បាឡែន ថនិកសត្វខ្លះទៀតនៅលើអាកាសដូចជាប្រចៀវ ឬជ្រឹង ។

អាទិត្យទី ២ នឹងទី៣.– គេចែកថនិកសត្វច្រើនពួកៈ ពួកទី១ គឺថនិកសត្វណាដែលស៊ីសាច់ជាអាហារ ហើយមានចង្កូម ទន់ក្រញាំ ចូកណាស់ដូចឆ្មា, ខ្លាធំ, ខ្លារខិនជាដើមគេហៅថា មំសាហារសត្វ ថនិកសត្វខ្លះទៀតស៊ីស្មៅជាអាហារ ដូចជាគោ ក្របី - ដាម - ពពែជា សត្វទំពាអៀង មួយពួកទៀតដូចជា ទន្សាយ - សេះ - ដំរី - ជ្រូក-ស្រុក ជ្រូកព្រៃ ជាសត្វមិនទំពាអៀង ។ ពួកថនិកសត្វណាដែលស៊ីស្មៅជាអាហារគេហៅថា តិណាហារសត្វ ។ ថនិកសត្វមួយពួកទៀតដែលស៊ីសត្វល្អិត ៗ ជាអាហារដូចជាប្រចៀវ ឬក្រឹងគេហៅថា បាណកាហារសត្វ ។

## អាទិត្យទី ៤ បក្សី

ប្រដាប់សម្រាប់បង្រៀន មាន់

លក្ខណៈ បក្សី– មាន់មានលក្ខណៈប្លែកពីថនិកសត្វដូចម្ដេចខ្លះ ៗ មានរោមពាសខ្លួន ៗ មានជើងប៉ុន្មាន ៗ មានធ្មេញឬទេ ៗ មានបង្កើតកូន តែម្ដងឬពងសិន ៗ

បក្សីជាសត្វឈាមក្តៅគ្មានដោះទេ រោមវាមានបីយ៉ាង៖ រោមណាវែង ៗ ដុះនៅស្លាបនិងកន្ទុយ រោមខ្លី ៗ ដុះនៅពាសពេញខ្លួនវា ចំណែករោមសំឡីដុះនៅក្រោមរោមវែងនិងរោមខ្លី ៗ គឺរោមសំឡីនេះហើយដែលបក្សីទុកដូចជាភួយដើម្បីការពារនឹងធាតុត្រជាក់ ៗ ចំពុះវារឹង មានស្លាបពីរជើងពីរ ហើយជើងមួយ ៗ មានម្រាម ៤ បេះហើរ-បេះដើរ ហើយបង្កើតកូនដោយពង ៗ ក្នុងពួកបក្សីមានបក្សីស្រុក ដូចជាមាន់ ទា ។ល។ និងបក្សីព្រៃដូចជាខ្លែង ក្អែក ចាប ។ល។ មានបក្សីច្រើនហើររកស៊ីតែថ្ងៃ គេហៅថាបក្សី ទិវាចរ ខ្លះដូចជាមៀម ទីទុយចេញហើររកស៊ីតែយប់ គេហៅថាបក្សី រាត្រីចរ ៗ

បក្សីខ្លះដូចជាទា ក្ងាន ស្មោញ ប្រវឹក ទុង មានម្រាមជើងជាប់គ្នានឹងស្បែក វាហែលទឹកបានដោយងាយ សត្វនេះដើរនៅដីមិនបានលឿនទេ ៗ បក្សីខ្លះមានជើង ក- ចំពុះ វែងប្រយោជន៍នឹងឲ្យងាយរកចំណីអាហារស៊ីក្នុងភក់ក្នុងទឹកជ្រៅល្មមៗដូចជាក្រសារ ក្រៀល កុក កន្ទុំ ត្រដក់ មាន់ទឹកខ្វក ៗ

តាមធម្មតាគ្រប់តែបក្សី គឺបក្សីតូច ៗ ជាដើមនោះ ជាសត្វមានប្រយោជន៍នឹងយើង ពីព្រោះវាស៊ីដង្កូវ-កំពោធ ហើយនិងបាណកជាតិចាំង

ឡាយដែលបំផ្លាញដំណាំយើង ហេតុដូច្នេះចូរយើងប្រយ័ត្ន កុំសម្លាប់វា កុំធ្វើឲ្យអន្តរាយសំបុកវាឲ្យសោះ ។

## វិធីបង្ការរោគ

### អាទិត្យទី១ - ការថែរក្សាទីលំនៅ

ត្រូវរើសកន្លែងសង់ផ្ទះ ៖ នៅទីក្រុងត្រូវសង់តាមវិថីធំៗ នៅស្រុកស្រែត្រូវរើសទីទួលនៅឆ្ងាយពីទីថ្លុកត្រពាំងឬផ្លូវទឹក ។ គួរសង់ផ្ទះឲ្យបានបែរមុខទៅខាងត្បូង ។ ដើមឈើទាំងឡាយធ្វើឲ្យអាកាសបរិសុទ្ធ ហើយតែកុំឲ្យដាំជិតផ្ទះពេក ដើម្បីទុកឲ្យពន្លឺព្រះអាទិត្យនិងអាកាសចូលក្នុងផ្ទះ ។

ត្រូវសង់ក្រោលគោ-ក្របី-សេះ-ទ្រុងជ្រូក-មាន់-ទា និងបង្គន់ឲ្យឆ្ងាយពីផ្ទះ ។

រាល់ព្រឹកត្រូវបើកទ្វារបង្អួចទាំងអស់ត្រូវបោសក្តារក្រាលថ្នមៗ កុំឲ្យធូលីហុយឡើងត្រូវជូតគ្រឿងតុ-តាំង ដោយសំពត់សើមត្រូវរើពូកខ្នើយ-ភួយ-កន្ទេល-មុង ហាលថ្ងៃឲ្យបានញយៗ ។ ត្រូវបោសទីកួមឲ្យបានស្អាតជានិច្ច ហើយត្រូវដុតសម្រាមចោល ។

សុភាសិត - កន្លែងណាដែលមានពន្លឺព្រះអាទិត្យចូល កន្លែងនោះពុំសូវមានមេរោគទេ ។

## អាទិត្យទី ២ - សត្វរស់នៅនឹងខ្លួនមនុស្ស

សត្វរស់នៅនឹងខ្លួនមនុស្សមានពីរពួក ៖ មួយពួកដែលយើងអាចមើលឃើញដូចជាចៃ, សង្កើច, មូស, ព្រូននឹងមេក្រមរមាស់ ។ មួយពួកទៀតយើងមើលដោយភ្នែកពុំឃើញទេគឺជា :

អតិសុខុមប្រាណ ដែលអាចចម្លងជម្ងឺ : គ្រុនធ្ងន់, គ្រុនសាចុះឡើង, ឃ្លង់ ។

មានចៃពីរយ៉ាង : ចៃក្បាល ១ យ៉ាង ចៃខ្លួនឬចៃសំពត់អាវ ១ យ៉ាង ចៃទាំងអស់សុទ្ធតែស្មោកគ្រោកដូចគ្នា គួរឲ្យខ្ពើមណាស់ ចៃក្បាលច្រើននៅក្នុងផ្នួងសក់ ច្រើននៅក្នុងសក់ក្បាលមនុស្សណាដែលវែង ៗ ចៃខ្លួន ឬ ចៃសំពត់អាវច្រើនមាននៅដោយសំលៀកបំពាក់ ហើយចូលចិត្តនៅតែសំលៀកបំពាក់ណាដែលប៉ះពាល់ផ្ទាល់នឹងស្បែក

ត្រូវប្រយ័ត្នកុំឲ្យសង្កើចនៅក្នុងដំណេក ។ ត្រូវដេញបំបាត់មូសកុំឲ្យវាខាំ ពីព្រោះមូសខាំបណ្តាលឲ្យទៅជាគ្រុនចាញ់ ។ ព្រូនច្រើន

នៅក្នុងពោះវៀន ។ សត្វនេះកើតមកអំពីចំណីអាហារមិនឆ្អិន ។ រមាស់បណ្ដាលកើតមកពីការស្មោកគ្រោក ។

## អាទិត្យទី៣ – ជម្ងឺស៊ើស្បែក

សេចក្ដីរំឭក. ជម្ងឺស៊ើស្បែកទាំងប៉ុន្មាន (កម ប៉ូសទ្រេនិច ប៉ូសបណ្ដើរកូន ដំបៅឆ្អា ដំបៅពក). សុទ្ធសឹងបណ្ដាលពីមេរោគទាំងអស់ ដែលជាហេតុនាំឲ្យឆ្លង ដូច្នេះ កុមារដែលកើតរោគនេះគាន់តែសំអាតខ្លួនឲ្យណាស់ ត្រូវកាត់ក្រចកដៃឲ្យអស់ពេញ ត្រូវរកថ្នាំលាបទើបជា ។ ឯកុមារដែលគ្មានកើតរោគនេះ ត្រូវកុំឲ្យប៉ះពាល់នឹងកុមារឈឺ ឬ ក៏យករបស់អ្វីនៃកុមារនេះមកប្រើប្រាស់ឲ្យសោះ ៕

## អាទិត្យទី៤.– កិច្ចដែលត្រូវធ្វើក្នុងពេលមានរោគរាតត្បាត

អាសន្នរោគ ពិស ផ្កាំងហៅថា ប៉េស្ដ ។

ចំពោះជម្ងឺអាសន្នរោគ - ១– ត្រូវដាំទឹក - ចំអិនបន្លែឲ្យឆ្អិនហើយគ្របចំណីអាហារកុំឲ្យរុយទំ ។ ២– ត្រូវស្អាតឲ្យណាស់ ។ ៣– ត្រូវចាក់ថ្នាំការពារខ្លួន ។ ចំពោះជម្ងឺប៉េស្ដ - ដូចគ្នានឹងជម្ងឺអាសន្នរោគដែរ តែត្រូវជៀសវាងសង្កើចនឹងត្រូវចាប់កណ្ដុរសម្លាប់ដុតចោល ។

មេរៀនសង្ខេប .— រុយបណ្ដាលឲ្យឈឺអាសន្នរោគ មូសបណ្ដាលឲ្យឈឺគ្រុនចាញ់ ចៃបណ្ដាលឲ្យកើតពិស ពិសបារាំងហៅថា "ប៉េស្ដ" ជាជម្ងឺរបស់នាំឲ្យមនុស្សស្លាប់រង្គំរង្គាលជាច្រើនផង ។ ជម្ងឺរបស់នេះបណ្ដាលមកពីចៃរាបម្លងជម្ងឺពិសនេះទៅមនុស្ស ពីព្រោះចៃខាំកណ្ដុរដែលកើតពិស លុះវាមកខាំមនុស្សទៀត វាបញ្ចូលមេរោគពិសនោះមកក្នុងខ្លួនមនុស្ស ។ ហេតុដូច្នេះ បានជាថាជម្ងឺពិស គឺជាជម្ងឺកណ្ដុរឆ្លងតៗគ្នាមកមនុស្សដោយសារចៃ ។ ត្រូវធ្វើបំបាត់កណ្ដុរកុំឲ្យមានជាដរាប កាលណាមានកើតជម្ងឺពិសក្នុងស្រុក ត្រូវដុតឡោចកណ្ដុរដែលអ្នកប្រទះឃើញហើយត្រូវចាប់ចៃចោលផង ។

---

## បរិបូណ្ណាង្គ

### វត្ថុស្វាធ្យាយន៍

អាទិត្យទី១ .— ១ អំពីអាហារ

របស់សំរាប់បង្រៀន ៖ អង្ករ - ម្សៅនំបុាំង - នំបុាំង ។

នាំសិស្សនិយាយពោលសួរឲ្យឆ្លើយដូចមានរបៀបខាងក្រោមនេះ ។

អ្នកបរិភោគអ្វីជាអាហារ ? ជាតិណាខ្លះបរិភោគបាយដូចយើង ។ បាកាំងបរិភោគបាយដូចយើងដែរឬទេ ? ជាតិណាខ្លះដែលអាស្រ័យ-នំបុ័ង ? គេបំពិនបាយដូចម្ដេច ? នំបុ័ងយ៉ាងដូចម្ដេច ? បើស៊ីបាយទទេបានឬទេ ? ឯងអាស្រ័យបាយនឹងអ្វីខ្លះ ? ។

## ២– អំពីបន្លែ

របស់សំរាប់បង្រៀន ៖ ប៉េងប៉ោះ, ត្រប់-ដំរ-សាឡាត់ដំឡូង-ផ្លែឈើអ្វីទៅទៀត ។ ឲ្យសិស្សរកម្នាក់មួយមុខៗ បន្លែឯទៀត ។

ពាក្យសួរ.— យើងបរិភោគបន្លែណាខ្លះ ? ឲ្យសិស្សម្នាក់ចាំបង្ហាញបន្លែមួយមុខៗ ។ បន្លែណាខ្លះដែលគេបរិភោគស្រស់ឆៅ ? អន្លក់គេបរិភោគដូចម្ដេច ? អ្វីខ្លះដែលយើងបរិភោគជាអន្លក់ ។ (ស្លឹកកាំង-សាឡាត់-ដំរ-ខាត់ណាៗលៗ) នៅក្នុងដំឡូងមានជាតិអ្វី? (កាប់ដំឡូងឆៅមួយឲ្យសិស្សមើលជាតិម្សៅ) ។ បន្លែណាទៀតដែលមានជាតិម្សៅ ? ផ្លែឈើណាខ្លះ ដែលយើងបរិភោគជាកល់ថ្ងៃជាអាហារ ?

អាទិត្យទី ២.— អំពីត្រី

ឲ្យសិស្សរកត្រីស្រស់ - ត្រីងៀត - ត្រីឆ្អើរ ផ្អក · ប្រហុក ។

ពាក្យបោទ.— គេយកត្រីមកចំអិនធ្វើបានម្ហូបអ្វីខ្លះ? បើទុកឲ្យបានយូរគេយកត្រីទៅធ្វើដូចម្តេចខ្លះ? គេប្រឡាក់ - ឆ្អើរត្រីដូចម្តេច? ។ល។ គេបរិភោគប្រហុករបៀបដូចម្តេច? ។

២- សត្វស្រុកដែលគេយកសាច់ជាអាហារ របស់សំរាប់បង្រៀន សាច់ជ្រូក - សាច់គោ - សាច់ក្របី · សាច់មាន់ ។ល។

អាទិត្យទី ៣.— ១ សត្វព្រៃដែលគេយកសាច់ជា អាហារ

២.— ទឹកដោះគោ

របស់សំរាប់បង្រៀន ទឹកដោះគោឆៅ ខ្លាញ់ប៊ឺ ហ្វ្រូម៉ាស-(បើមាន)

អាទិត្យទី ៤.— អំពីស៊ុត (ពង)

សូមគ្រូតែងពាក្យសួរផងចុះ

## វិធីបង្ការរោគ

អាទិត្យទី ១.— ១ ត្រូវបរិភោគល្មមសមគួរ ។

មើលក្នុងសៀវភៅវិធីបង្ការរោគទំព័រ ២៤

២ ត្រូវបរិភោគអាហារដែលល្អឥតទោស ។

អាទិត្យទី២.— ១ ត្រូវបេះផ្សំចំណីអាហារ

២ ត្រូវចំអិនសាច់ទឹកអាហារឲ្យល្អ

អាទិត្យទី៣.—៤ ត្រូវបរិភោគតាមសំរួល ហើយទំពាឲ្យល្អិតផង ។

សូមគ្រូមើលក្នុងសៀវភៅវិធីបង្ការរោគចុះ ។

---

# កុមារដ្ឋាន

## វិត្យាធ្យាយន៍

### អាទិត្យទី ១ — អំពីខ្លួនមនុស្ស

គ្រូចាត់សិស្សម្នាក់ឲ្យទៅឈរនៅមុខសិស្សឯទៀត សួរហើយឲ្យសិស្សម្នាក់ ៗ ចង្អុលប្រាប់សិស្សទាំងឡាយថា នេះហៅក្បាល ? នេះ-លលាដ៍ក្បាល ។ល។ ត្រូវឲ្យសិស្សម្នាក់ ៗ ស្ទាបក្បាលលលាដ៍ក្បាលខ្លួនឯងរៀងៗគ្នា ។ល។

ពាក្យសួរ.- ឯណាក្បាល ? ឯណាមុខ ?

ក្បាលរាងដូចម្ដេច ? ក្បាលភ្ជាប់ទៅដងខ្លួនដោយអ្វី? ។ សក់ដុះនៅឯណា ? សក់ក្មេងពណ៌ដូចម្ដេច ? ចុះសក់មនុស្សចាស់វិញ ? នៅលើមុខមានអ្វីខ្លះ ? ( ឲ្យសិស្សចង្អុលគ្រប់ ៗ គ្នា ) ភ្នែកសំរាប់ធ្វើអ្វី ? ចិញ្ចើមនឹងរោមភ្នែកមានប្រយោជន៍ដូចម្ដេច ? ច្រមុះសំរាប់ធ្វើអ្វី ? នៅក្នុងមាត់មានអ្វីខ្លះ ? យើងស្ដាប់ឮដោយសារអ្វី? ។ ល ។

## អំពីដងខ្លួន

គ្រូឲ្យសិស្សម្នាក់ ទៅឈរនៅមុខសិស្សឯទៀតហើយឲ្យដោះអាវចេញទើបលោកគ្រូចង្អុលអវយវផ្សេង ៗ ។

ពាក្យសួរ.- ឯណាហៅថាដងខ្លួន ។ ដងខ្លួនខាងលើហៅថាអ្វី ? ខាងក្រោមហៅថាអ្វី ? ឯណាឆ្អឹងជំនី ? ឯណាឆ្អឹងខ្នង ? យើងពត់ខ្លួនបានទៅខាងណាខ្លះ ? ដោយហេតុអ្វី ? ឆ្អឹងខ្នងយើងមិនមែនជាឆ្អឹងមួយដុំវែងនោះទេ ? គឺជាឆ្អឹងកំណាត់ខ្លី ៗ ត្រួត ៗ លើគ្នា ហេតុនេះហើយបានជាយើងពត់ខ្លួនទៅខាងណាក៏បាន ។ នៅក្នុងទ្រូងមានអ្វីខ្លះ ? ( បើមានផ្ទាំងគំនូរត្រូវយកមកបង្ហាញសិស្សឲ្យស្គាល់

ស្អួត- បេះដូងហើយនឹងក្រពះ- ពោះវៀន- ថ្លើម- ប្រមាត់- ដែលនៅក្នុងពោះមើលពុំឃើញ )

អាទិត្យទី២ .- ១- អវយវៈ លើក្រោម

សូមគ្រូធ្វើតាមរបៀបមុនៗ ចង្អុលបង្ហាញសិស្ស ឯណាហៅថាដៃ ដើមដៃ- កែងដៃ- កំភួនដៃ- កដៃ- បាតដៃ- ខ្នងដៃ- ម្រាមដៃ- ថ្នាំងដៃ- ក្រចក- ជើង- ភ្លៅ- ជង្គង់- កំភួនជើង- កជើង- ក្នុកគោរ កែងជើង- បាតជើង- ខ្នងជើង- ម្រាមជើង ។

សូមគ្រូពន្យល់ប្រយោជន៍នៃសន្ទាក់ដៃជើងនិមួយ ៗ ឲ្យសិស្សឃើញច្បាស់ ។

## ២_ ភ្នែក

អាទិត្យទី៣ .- ១- ត្របៀក ២- ប្រមុះ ។

អាទិត្យទី៤ .- ១- អណ្តាត ២- ស្បែក ។

## វិធីបង្ការរោគ

អាទិត្យទី ១ .- ការថែរក្សាសក់

សូមគ្រូបង្រៀនតាមសៀវភៅវិធីបង្ការរោគទំព័រ៤៣

អាទិត្យទី២.- ត្រូវធ្វើកុំឲ្យមានចៃ

សូមមើលក្នុងសៀវភៅដដែលទំព័រ ៤៦ ។

អាទិត្យទី៣.- ត្រូវមើលជម្ងឺរមាស់

ជម្ងឺរមាស់ពុំដែលជាឯងទេ ហេតុដូច្នេះត្រូវតែមើលដូចតាមរបៀបខាងក្រោមនេះ ៖

ត្រូវដុសខ្លួននឹងសាប៊ូខ្មៅ ដុសក្តួតនឹងសាប៊ូខ្មៅឲ្យយ៉ាងខ្លាំង គម-នេះនឹងបែកហើយមេពោកអាត់នឹងពងអាត់របើកចេញពីរន្ធ រួចត្រូវងូតទឹកដុសសាប៊ូលាបថ្នាំស្ពាន់ធ័រទុកមួយថ្ងៃ ទើបងូតទឹកក្តៅលាងខ្លួនចេញ ។ បើនៅមានមេអាត់ទៀតត្រូវធ្វើដដែលឡើងវិញម្តងទៀត ។

ត្រូវស្ងោរខោអាវឲ្យស្អាតហើយដេកលើកំរាលស្អាត ។

អាទិត្យទី៤.- សាបស្រៀនឡើងវិញ ។

---

## លោកនីតិ

សំរាប់គ្រប់ថ្នាក់

## អំពីសំបុត្រកំណើត

សំបុត្រកំណើតមានប្រយោជន៍ណាស់ ហេតុនេះត្រូវកុំធ្វេស

ប្រហែសឲ្យសោះ បើមានកូនកើតរវាងបីថ្ងៃត្រូវរកសាក្សីបានពីរនាក់ ហើយនាំគ្នាទៅសាលាឃុំប្ដឹងសុំចុះកំណើតកុមារនោះ ហើយត្រូវសុំចម្លងកំណើតមួយច្បាប់ទុកប្រើការទៅថ្ងៃក្រោយ ដូចចូលទៅរៀនក្នុងសាលា ឬបង់កាតឬបួសឬទាស់ទែងគ្នាដល់តុលាការអំពីសម្បត្តិមត៌កក្ដី ត្រូវមានជាតិសញ្ញាប័ត្រដំរាប ។

បើនៅក្រុងភ្នំពេញ កាលណាមានកូនកើតត្រូវទៅប្ដឹងមេសង្កាត់ (មេឃុំ) ក្នុងពេលដែលកើតនោះ ទើបមេឃុំចេញសំបុត្រមួយឲ្យគាត់យកទៅមន្ទីរព្យាបាលរោគ ដើម្បីឲ្យពេទ្យការពាររោគទៅបណ្ដុះអុត-កុមារនោះក្រោយរួចបាននាំទៅចុះកំណើតនៅសាលាឃុំវិញក្នុងកំណត់បីថ្ងៃ ។

ពាក្យសួរចោទ.- បើមានកូនកើតត្រូវធ្វើដូចម្ដេច? នៅភ្នំពេញគេធ្វើដូចម្ដេចទៀត? បើមិនបានទៅប្ដឹងមេឃុំឲ្យចុះកំណើតទេនោះនឹងមានទោសដូចម្ដេច? (លក់ពិន័យ) សំបុត្រកំណើតមានប្រយោជន៍យ៉ាងដូចម្ដេចខ្លះ? ។

## សំបុត្រអាពាហ៍ពិពាហ៍ (អាវាហវិវាហ)

មុននឹងរៀបការកូនប្រុស-ស្រីត្រូវមាតាបិតាខាងកូនស្រី ទៅប្ដឹងមេឃុំចំនួន ៨ ថ្ងៃមុនរៀបមង្គលនេះ មេឃុំត្រូវចេញសំបុត្រមួយច្បាប់មាន-

ចុះឈ្មោះស្វាមីខ្លួនប្រុស-ស្រីហើយបញ្ញត្តថា បើឈ្មោះណាមានទាក់ទង-នឹងនាងនេះនឹងអ្នកនេះ ត្រូវប្ដឹងតវ៉ាក្នុងរវាង៨ថ្ងៃមុននឹងរៀប អាពាហ៍វិវាហ៍ តែបើហួសកំណត់ថ្ងៃនេះហើយនឹងទុកជាស្រេច លុះរៀបអាពាហ៍ពិពាហ៍ស្រេចហើយ មាតា-បិតានឹងកូនប្រុស-ស្រីមានសាក្សីពីរនាក់ នាំគ្នាទៅចុះអេតាស៊ីវិលនៅសាលាឃុំ រួចសុំសំណៅមួយសន្លឹកទុកប្រើការទៅពេលក្រោយ ពីព្រោះមានច្បាប់បញ្ញត្តថា នរណាយកគ្នាជាប្ដីប្រពន្ធពុំបានចុះអេតាស៊ីវិលនោះមិនពេញជាប្ដីប្រពន្ធទេ បើមានហេតុទាស់ទែងលែងលះគ្នានោះ រាជការមិនទទួលបណ្ដឹងឡើយ បដិសេធចោលជាអសារ-ឥតការ ។

សួរទេ.– សូមសួរទេ នាំសិស្សនិយាយឲ្យបានបេះប្រាកដដូចមានរបៀបមុនៗស្រាប់ ។

## មរណភាព

របៀបកើតនឹងស្លាប់មិនប្លែកគ្នាប៉ុន្មានទេ នៅទីក្រុងបើមានមនុស្សស្លាប់គេទៅប្ដឹងសុំសំបុត្រមេឃុំ រួចយកសំបុត្រនោះទៅមន្ទីរការពាររោគដើម្បីឲ្យគ្រូពេទ្យទៅពិនិត្យមើលខ្មោចនោះ តើស្លាប់ដោយរោគអ្វី ៗ លុះពេទ្យពិនិត្យមើលត្រឹមត្រូវហើយ ទើបអនុញ្ញាតឲ្យយកខ្មោចនោះទៅកប់ ឬ

រួចជាតាមកំណត់ពេលវេលា ដែលគ្រូពេទ្យបានបញ្ញត្តក្នុងសំបុត្រនោះស្រាប់ ៗ រួចពីនោះមកបីថ្ងៃទើបបានគេនាំគ្នាទៅចុះមរណភាពឯសាលា-ឃុំដូចជាចុះកំណើតនោះដែរ ៗ

---

# មេសូត្ររត់មាត់

(សំរាប់គ្រប់ថ្នាក់)

## ១- សេចក្តីស្នេហាចំពោះបងប្អូន

បងប្អូនប្រុសស្រី ទោះតូចធំក្តី គោរពស្រឡាញ់គ្នា
រាប់អានស្នេហ៍ស្និទ្ធ ធ្វើចិត្តមេត្តា កុំទាស់ទែងគ្នា
ជាការមិនល្អ ៗ បងត្រូវថ្នមប្អូន ឲ្យដូចជាកូន
ចេញពីខទេរ ប្អូនត្រូវគោរពខ្លាច កុំអាចតបត
ទើបអ្នកបានល្អ បវរពេកក្រៃ ៗ ចរចារកគ្នា
ប្រើពាក្យសោភា បន្ទន់សំដី ពោលចំពោះប្អូន
ចំពោះបងក្តី គោរពតែគិតគែ លៃលកឲ្យសមរ
ទើបអ្នករក្សា សុខឥតទុក្ខា មកលាយប្រឡំ
ព្រោះតែអ្នកប្រើ សំដីគួរសម ឥតឆ្គងឥតឆ្គាំ

រូបរួមបិតថេរ ។ កិច្ចការពក់ជ្រៅ បងត្រូវប្រដៅ
ដោយចិត្តស្និទ្ធស្នេហ៍ ប្អូនមានកំហុស គិតខុសវៀចវេរ
ទំនាស់ក្នុងគេ ប្រាប់កុំបង្អង់ ។ ម៉្យាងទៀតជេដ្ឋា
ត្រូវកាន់កិរិយា រក្សាដៅពង្ស ធ្វើខ្លួនឲ្យល្អ
ស្មោះសរស្លូតត្រង់ ការកេរ្តិ៍ពូជវង្ស ឬជាតម្រា ។
ប្អូនធ្វើតាមក្រោយ ពុំហ៊ានបណ្តោយ តែងតែធ្វើត្រាប់
ប្រព្រឹត្តកោតក្រែង យកបងជាច្បាប់ ធ្វើបេះពាល់ស្លាប់
ពុំបែកគ្នាឡើយ ។

ពាក្យពន្យល់.- ថេរ = គោះ, ថ្ពុ ។ បវរ = (ម.ថ. ប.រ")

ប្រសើរ សោភា = សម, ល្អ ។ ជេដ្ឋា = បង ។

ស្មោះសរ = សេចក្តីកែកាយពក់ទាក់ ។

## ២.- អំពីដែក

ដែកមានប្រយោជន៍ ឥតគ្មីប្រដូច ដល់ពូជដែកឡើយ គេរកឃើញច្បាស់ ប្រាកដជាក់ហើយ មានមិនឆ្ងាយឡើយ ក្នុងកម្ពុជា ។ ស្រុកកំពង់ស្វាយ រន្ទើស្ទុះសាយ ដីងព្រួគ្រប់គ្នា ខេត្តកំពង់ធំ កើតដូចបព្វតា បើចង់បានវា កាយជុតក្នុងឡ ។ នៅស្រុកគីរ៉ុប គេធ្វើ

សព្វគ្រប់ កាយវាមកគរ បានច្រើនហើយទើបបញ្ចូលក្នុងឡ ដុត ហើយទើបកកើតជាដែកស្វិត ៗ ដែកនេះផុយខ្វៅ ព្រោះជាប់ធ្យូងទៅ ជាអាចម៍ដែកពិត គេធ្វើដែកថែប ដុតភ្លើងសរិត សំរាំងពិនិត្យ ដេញអាចម៍ឲ្យអស់ ៗ ចំណែកដែកស្វិត ជាដែកផុយពិត ព្រោះលាយអាចម៍នោះ គេធ្វើឆ្នាំងខ្ទះ ចង្ក្រានដូបឆ្នោះ កូនជញ្ជីងព្រោះ ជាដែកផុយស្រួយ ៗ ប៉ែកខាងដែកថែប គេធ្វើគ្រប់បែប ពិសិដ្ឋលេខមួយ ពិសេសថៃថ្វា ជាប់ស្និទ្ធឥតស្រួយ ធ្វើអ្វីពុំព្រួយ មុតហើយរឹងផង ៗ ដូចកាំបិតការ កន្ត្រៃឬក៏ សាស្ត្រាវុធបុរាណ ឬម្ជុលក៏ដោយ មុតរឹងកន្លង គេប្រាថ្នាប៉ង់ ព្រោះជាប់ពេកក្រៃ ។

ពាក្យពន្យល់ ៖— បព្វតា = ក្នុំ ៗ សរិត = ធ្វើឲ្យស្អាត ៗ សំរាំង = ធ្វើឲ្យស្រាំង, ជ្រើសរើសយកតែល្អ ៗ

---

## ៣– ការធ្វើស្ករ

ទឹកត្នោតកើតជាស្ករ
មានសម្បូណ៌គំពង់ស្ពឺ
កំពតពីរអន្ទើ
នេះគេធ្វើស្ករច្រើនណាស់ ៗ
ដំបូងគេយកឃ្នាប
ច្របាច់តាមប្រែក្រឡះ

សង្កេតឃើញទន់ប្យាស់ ថាទឹកអាចហូរធ្លាក់បាន ។
ទើបគេបិតចុងផ្កា ទឹកហូរហៀរចេញតាកឋាន
ហើយគេវៀលវិធថ្កាន ទៅឯផ្ទះយកបំពង់ ។
ដែលធ្វើពីឫស្សី ប្រញាប់ខ្ចីយកមកត្រង់
គឺគេយកទៅចង ក្រោមផ្កាហោងពេញផ្ទុស់ទៀត ។
ការពារក្រែងជូរខក យកសំបកពពេលជាតិ
រំបតមកដាក់ទៀត ក្នុងបំពង់ឫស្សីនោះ ។
ឬសំបកគគីរ ដែលមានជីជាតិជូរចោះ
ដាក់គ្រប់បំពង់អស់ ទឹកត្នោតនោះឥតជូរឡើយ ។
ទឹកត្នោតទុជាធ្លាញ់ គេបំពាញ់ឲ្យខាប់ហើយ
យកឈើពុំយូរឡើយ មកកូរឲ្យសុក្កពណ៌ ។
ទើបដាក់ទៅក្នុងពុម្ព ស្ករត្នោតរុំជាពុម្ពស្ករ
ទុកយូរបន្តិចកំ ក្លាយជាស្ករផែនដុំមូល ។
ជួនកាលគេរំងាស់ ទឹករំងែអស់ខាប់បញ្ចូល
ក្នុងក្អមឬប្រមូល ចាក់ចូលក្នុងប៉ោតទុកនៅ ។

ពាក្យពន្យល់ ៖ – ទុជា = អ្វីដែលបង្កើតកម្លាំង ។

បំពាញ់ = បំហៀរ, រំងាស់

សុក្កពណ៌ = ពណ៌ស ។

## ៤- ផ្លូវនិងជំនួញនៅស្រុកខ្មែរ.

ផ្លូវទៅក្នុងស្រុកខ្មែរ ហូរហែរបរិបូណ៌ណាស់
ត្រូវយើងដឹងឲ្យច្បាស់ ស្រួលពេកណាស់គ្រប់ប្រកល្អ ។
យើងនាំទំនិញទៅ ប្រទេសក្រៅនាំចូលមក
ចង់បានអ្វីចេញរក គេចូលមករកវិញបាន ។
ព្រោះមាន ៤ ទន្លេ នោះជាមេជលដ្ឋាន
ចេញចូលជិតឆ្ងាយបាន គេសន្និដ្ឋានថាមេគង្គ ។
ទន្លេមេគង្គឯង ខាងជើងបែងស្រុកលាវលង់
ជួនកោងជួនក៏ត្រង់ ឯទន្លេសាបវិញនៃ ។
ខាងលិចទៅដល់ ព្រំប្រទល់នឹងស្រុកថៃ,
ទន្លេពីរទៀតនៃ នៅខាងត្បូងជាប់គ្នាជិត ។
មួយគឺទន្លេក្រៅ មួយទៀតហៅមាត់ជ្រូកពិត
នាំអ្វីបានតាមចិត្ត ផ្លូវទៅពិតកូសាំងស៊ីន ។

ពាក្យពន្យល់.— ជលដ្ឋាន: (ម.ថ. ជល់-ល័ត-ឋាន) ទីទឹក ។ សន្និដ្ឋាន: (ម.ថ. សន់-និត-ឋាន) សេចក្ដីចូលចិត្ត, យល់ ។

## ៥_ ផ្លូវនឹងជំនួញនៅស្រុកខ្មែរ (ត)

ចំណែកផ្លូវគោកវិញ　　រថចូលចេញគ្រប់ខេត្តដែន
ទំនិញផ្ទុកពេញណែន　　ឬដឹកនាំអ្នកដំណើរ ៗ
ផ្លូវបាត់ដំបងមាន　　រថភ្លើងយានយ៉ាងប្រសើរ
ស្រួលដល់អ្នកដំណើរ　　ដែលស្វែងដើរជំនួញក្ដី ៗ
ការគមនាគមន៍　　ពជការរំធ្វើស្រួលក្រៃ
ផ្លូវណាដែលមានព្រៃ　　គេកាប់ចោលឥតទុកទេ ៗ
ជំនួញដែលធំ ៗ　　ដ៏ឧត្តមចេញពីខ្មែរ
ទៅលក់ប្រទេសគេ　　ស្រូវ, ត្រីងៀត, គោ, ស្បែក, ស្នែង ៗ
កប្បាសនេះជាដើម　　ដែលគេផ្ដើមចេញពីឯង
សំពត់គ្រឿងតាក់តែង　　ឬដែលតែងមកពីគេ ៗ
ពីនេះតទៅមុខ　　សង្ឃឹមទុកក្នុងចិត្ត
យើងក្រៀមបាកទុក្ខ　　តាំងយើងគេគ្រប់រូបប្រាណ ៗ

ពាក្យពន្យល់.-- គមនាគមន៍=( ម. ថ· គ: · ម: · នា · គំ ) ដំណើរទៅមក ៗ ចិត្ត= ( ម. ថ· ចិត. តេ ) តម្រូវតាមពាក្យកាព្យ= ចិត្ត ៗ ទុក្ខ= ( ម. ថ. ទុក. ខ ទុក្ខ ៗ

## ៦– ឧបាយកលអ្នកស្រែម្នាក់

កាលនោះអ្នកស្រែម្នាក់ យល់ប្រត្យក្សថាអាត្មា
ជិតដល់កាលមរណា អស់សង្ខារក្នុងពេលឆាប់ ។
កូនប្រុសគាត់មានបី គាត់ឃ្លាតខ្លីហៅមកប្រាប់
ថាប្ដូរអ្នកប្រុងស្ដាប់ ឪពុកប្រាប់ការណ៍ឧត្ដម ។
ឱកូនមាសឪពុក ! ឪផ្ដាំផ្ដុកឲ្យកូនចាំ
ស្រឡាញ់គ្នាប្ដូរកុំ ឈ្លោះគំនុំគុំគួនគ្នា ។
អំណើះពីឪទៅ កូនប្រុសនៅត្រូវស្នេហា
កុំឲ្យបែកប្រេះឆា ទាស់ទែងគ្នាណាឧត្ដម ។
ប្រាក់ណែនមួយក្រឡ ឪអង្វរឲ្យកូនចាំ
ភ្ជួរស្រែស្វែងរកកំ- ណាប់ប្រាក់ដែលឪកប់ទុក ។
លុះគាត់ថ្លែងវាចា ប្រាប់បុត្រាអស់ទំនុក
ទើបបុរសឪពុក ក្សិណក្ស័យជន្មក្នុងពេលនោះ ។
ឯកូនទាំងបីនាក់ ភ្ជួររកប្រាក់ពុំឃើញសោះ
គំនិតទ័លទាំងអស់ មិនឃើញព្រោះឧបាយកល ។
លុះភ្លៀងបង្អុរមក ស្រែជោរជោគសព្វឥតសល់

នាំគ្នាគិតខ្វាយខ្វល់ សាបហើយស្ទូងកុំឲ្យខាត ។
លុះដល់ខែមិគសិរ ស្រូវនោះផ្លែទុំសព្វាត
នាំគ្នាប្រឹងខ្មីឃ្មាត ច្រូតបោកបែនដាក់ជង្រុក ។
លៃពូជ, ចំអែតប្រាណ សល់ប៉ុន្មានយកទៅលក់
មានប្រាក់ល្បីក្នុងស្រុក តទៅមុខខំលើសដើម ។

ពាក្យពន្យល់– មរណា = សេចក្ដីស្លាប់ , ប៉ុន្តែក្នុងទីនេះ
ដើម្បីនឹងតម្រូវពាក្យកាព្យបានជាសរសេរមរណា ។
ការណ៍ = ហេតុ ។ ចរចា = និយាយ ។ ជន្ម = (ម. ថ. ជន៌)
ជីវិត ។ ឧបាយកល = ឧបាយយ៉ាងល្អិត, ល្បិច ។

រោងពុម្ពខ្មែរ